# នៅចំពោះមុខអង្គជំនុំជម្រះ

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦២)

ភាគីដាក់ឯកសារ៖ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2020, 17:05
CMS/CFO: Ly Bunloung

---

## បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គីមសួន
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

នៅចំពោះមុខ៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS (បម្រុង)

**សហមេធាវីការពារក្តី មាស មុត**

សូ មូស្សេរីនី

Suzana TOMANOVIĆ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គីម ម៉េងឃី

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Lyma NGUYEN

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់*ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា* ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣") ដើម្បីបើកកិច្ចស៊ើបសួរលើ យឹម ទិត្យ[1]។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ និងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយមានការចោទប្រកាន់បន្ថែម ប្រឆាំង យឹម ទិត្យ ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2]។ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបអង្កេតអនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[3] ហើយសហចៅក្រមស៊ើបអង្កេត បានរួមគ្នាចេញ*សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ*[4]។ បន្ទាប់ពីមានសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមមួយចំនួន សហចៅក្រមស៊ើបអង្កេតបានចេញ *សេចក្តីជូនដំណឹងលើកទីពីរ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ* នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧[5]។ សហព្រះរាជអាជ្ញាជាតិ បានដាក់

---

[1] សំណុំរឿង ០០៣ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ [ចាប់ពីពេលនេះទៅហៅថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣"]។

[2] សំណុំរឿង ០០៤ ឯកសារ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ [ចាប់ពីពេលនេះទៅហៅថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ]។ សំណុំរឿង ០០៤ ឯកសារ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ [ចាប់ពីពេលនេះទៅហៅថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ"]។ សំណុំរឿង ០០៤ ឯកសារ **D272/1** ចម្លើយតបទៅនឹង ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរ ទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ [ចាប់ពីពេលនេះទៅហៅថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី]។ សូមមើលផងដែរ សំណុំរឿង ០០៤ ឯកសារ **D196/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឯកសារ D196 ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ (បញ្ជាក់បំភ្លឺលើការបញ្ចូល ទីតាំងឧក្រិដ្ឋកម្មប្រាំ ទៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ)។

[3] សំណុំរឿង ០០៤ ឯកសារ **D359** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧។

[4] សំណុំរឿង ០០៤ ឯកសារ **D358** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧។

[5] សំណុំរឿង ០០៤ ឯកសារ **D368** សេចក្តីជូនដំណឹងលើកទីពីរ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧។

ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ស្នើសុំឲ្យលើកលែងការចោទប្រកាន់ ប្រឆាំង យឹម ទិត្យ ដោយផ្អែកលើមូលដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[6]។ បន្ទាប់មក គឺនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ស្នើសុំឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើបទចោទដែលមានក្នុងនោះ[7]។

2. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង ០០៤។ សហចៅក្រមស៊ើបអង្កេតជាតិ នៅក្នុងដីកាដំណោះស្រាយរបស់គាត់ បានលើកលែងការចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ដោយបានសម្រេចថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើជននេះ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងសម័យខ្មែរក្រហមនោះឡើយ[8]។ ដោយបានលើកលែងការចោទប្រកាន់ទាំងអស់លើ យឹម ទិត្យ រួចហើយ សហចៅក្រមស៊ើបអង្កេតជាតិ ពុំបានពិនិត្យមើលភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ នោះទេ ហើយ សហចៅក្រមស៊ើបអង្កេតជាតិ បានបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់[9]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា អ.វ.ត.ក មានយុត្តាធិការលើ យឹម ទិត្យ នៅក្នុងដីកាដំណោះស្រាយរបស់គាត់ ("ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ")[10] ហើយបានចេញសេចក្ដីសម្រេច លើអង្គសេចក្ដីនៃភាពអាចទទួលយកបាន នៅក្នុងដីកាសម្រេចដោយឡែក ("ដីកាសម្រេចលើភាពអាចទទួល

---

[6] សំណុំរឿង ០០៤ ឯកសារ [redacted] ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ កថាខណ្ឌ ៣៤, ៣៦។

[7] សំណុំរឿង ០០៤ ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ១១៥៥-១១៨៣។

[8] សំណុំរឿង ០០៤ ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សំណុំរឿង ០០៣ ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[9] សំណុំរឿង ០០៤ ឯកសារ **D383** ដីកាសម្រេចបដិសេធ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ១៣។

[10] សំណុំរឿង ០០៤ ឯកសារ **D382** ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ [ចាប់ពីពេលនេះទៅហៅថា "ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ"] សំណុំរឿង ០០៣ ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ [ចាប់ពីពេលនេះតទៅហៅថា "ដីកាដំណោះស្រាយរបស់ ស.ច.ស.អ"]។

យកបាន")[11] ដោយក្នុងនោះ គាត់បានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន នៅក្នុងសំណុំរឿង ០០៤។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេច ស្តីពីភាពអាចទទួលយកបាន បង្ហាញមូលដ្ឋានលម្អិត ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសំអាងហើយសម្រេចថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០១ នៅក្នុងសំណុំរឿង ០០៤ មិនអាចទទួលយកបាន[12]។ សំណៅបកប្រែជាភាសាអង់គ្លេស នៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវបានជូនដំណឹងដល់ភាគី នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩ ចំណែកសំណៅបកប្រែជាភាសាខ្មែរ នៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩។ សំណៅបកប្រែជាភាសាខ្មែរ នៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីភាពអាចទទួលយកបាន និងឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ដាច់ដោយឡែកពីគ្នា។

3. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើជាតំណាងអាណត្តិ ឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានច្រានចោលនៅក្នុងដីកាសម្រេចអំពីភាពអាចទទួលយកបាន (ម្ចាស់បណ្តឹងឧទ្ធរណ៍) ដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍នេះ។

## II. បទដ្ឋាននៃបណ្តឹងឧទ្ធរណ៍

4. វិធាន ៧៧*ស្ទួន* ចែងអំពីការពន្លឿនដំណើរការបណ្តឹងឧទ្ធរណ៍ ក្នុងការចេញសេចក្តីសម្រេច លើភាពអាចទទួលយកបាន លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យោងតាមវិធាន ៧៧*ស្ទួន* "ក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង អំពីសេចក្តីសម្រេចអំពីភាពអាចទទួលយកបាន នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវដាក់បណ្តឹងឧទ្ធរណ៍នេះ ដោយមានបញ្ជាក់អំពីមូលហេតុដែលថា សហចៅក្រមស៊ើបអង្កេត មានការភាន់ច្រឡំលើអង្គហេតុ និង/

[11] សំណុំរឿង ០០៤ ឯកសារ **D384** ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ [ចាប់ពីពេលនេះទៅហៅថា "ដីកាស្តីពីភាពអាចទទួលយកបាន"]។

[12] សំណុំរឿង ០០៤ ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩។

ឬ អង្គច្បាប់ ក្នុងការសម្រេចអំពីភាពអាចទទួលយកបាន នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដោយអនុលោមតាមវិធាន ២៣ *ស្ទួន*'[13]។

5. នៅក្នុងបណ្តឹងឧទ្ធរណ៍ "កំហុសលើអង្គច្បាប់ដែលបានលើកឡើង ត្រូវបានពិនិត្យ*ជាថ្មីឡើងវិញ* ដើម្បីពិចារណាថាតើ សេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬអត់ ហើយកំហុសលើអង្គហេតុត្រូវបានពិនិត្យឡើងវិញ ស្របតាមបទដ្ឋានស្តីពីភាពសមស្រប ដើម្បីសម្រេចថាតើ អ្នកវិនិច្ឆ័យឥតលម្អៀងទៅលើអង្គហេតុ ពិតជាមិនអាចធ្វើសេចក្តីសម្រេចផ្នែកអង្គហេតុ ដែលបានលើកឡើងនេះ ឬយ៉ាងណា"[14]។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

6. ភាគីក្នុងសំណុំរឿង ០០៤ ត្រូវបានជូនដំណឹងអំពីដីកាសម្រេចស្តីពីភាពអាចទទួលយកបាន នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ លោកស្រី ជេត វណ្ណលី បានដាក់សំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ ចំពោះបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៧*ស្ទួន* ហើយស្នើសុំអនុញ្ញាត ដាក់តែមួយភាសាសិន[15]។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត បានដាក់សំណើសុំទីពីរ ដែលសឹងតែដូចគ្នាទាំងស្រុង នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩[16]។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើសុំពន្យាររយៈពេល និងបង្កើនចំនួនទំព័រ ដោយបានពន្យារកាលបរិច្ឆេទលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពមិនអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ រហូតដល់ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពី ដីកាដំណោះស្រាយរបស់សហចៅក្រម

---

[13] វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិ.លើកទី៩)។

[14] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៤។

[15] សំណុំរឿង ០០៤ ឯកសារ **D384/1** សំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩។

[16] សំណុំរឿង ០០៤ ឯកសារ **D384/3** សំណើបន្ទាន់របស់សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹង សេចក្តីសម្រេចពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩។

ស៊ើបអង្កេតអន្តរជាតិ និងឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេច ស្តីពីភាពអាចទទួលយកបាន ជាភាសាខ្មែរ ព្រមទាំងបានបង្កើនចំនួនទំព័រដល់ ៤៥ ទំព័រ ជាភាសាអង់គ្លេស ឬ ៩០ ទំព័រ ជាភាសាខ្មែរ និងបានអនុញ្ញាតឱ្យដាក់តែមួយភាសាជាមុនសិន[17]។

7. បណ្តឹងឧទ្ធរណ៍នេះបានដាក់ទាន់ពេលវេលា ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរ នៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងឧបសម្ព័ន្ធ ខ នៃដីកាសម្រេចអំពីភាពអាចទទួលយកបាន ហើយស្របតាមការកម្រិតចំនួន ៤៥ ទំព័រ ជាភាសាអង់គ្លេស ដែលបានអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ។ ក្រោយពីទទួលបានការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជាភាសាអង់គ្លេស។ សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍ និងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍នេះ នឹងត្រូវដាក់ជូនក្នុងពេលឆាប់ៗ នៅពេលដែលការបកប្រែរួចរាល់។

## IV. សេចក្តីសន្និដ្ឋានបឋម

8. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សេចក្តីសន្និដ្ឋានបឋមចំនួនពីរដូចខាងក្រោម។

9. ចំណុចទី១ សិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដូចមានចែងនៅក្នុងឯកសារស្នូលរបស់ អ.វ.ត.ក ពោលគឺ វិធាន ២១ និងវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង និងតួនាទីសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងស្វែងរកការផ្សះផ្សាជាតិ ត្រូវតែជាគោលការណ៍ណែនាំ សម្រាប់អង្គបុរេជំនុំជម្រះ នៅក្នុងការពិនិត្យមើលឡើងវិញ លើដីកាសម្រេចស្តីពីភាពអាចទទួលយកបាន និងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន។

10. ដូច អ.ប.ជ បានទទួលស្គាល់រួចហើយ គោលដៅ និងគោលបំណងនៃវិធាន ២៣*ស្ទួន* គឺដើម្បីកំណត់លក្ខណៈវិនិច្ឆ័យ នៃភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំមែនដើម្បីកំណត់ ឬ រិតត្បិតទស្សនទាននៃបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ឡើយ[18]។ ដូច្នេះ វិធាន

---

[17] សំណុំរឿង ០០៤ ឯកសារ **D384/4** សេចក្តីសម្រេចលើសំណើបន្ទាន់ របស់សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ ជំទាស់ទៅនឹងសេចក្តីសម្រេច ស្តីពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។

[18] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦២។

២៣*ស្ទួន* ត្រូវអានរួមគ្នាជាមួយនឹងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលកំណត់គោលការណ៍គ្រឹះនៃ អ.វ.ត.ក រួមទាំង ឯកសារស្នូលរបស់ អ.វ.ត.ក ដែលត្រូវបកស្រាយដើម្បីការពារជានិច្ចនូវផលប្រយោជន៍ និងធានាថា សិទ្ធិរបស់ពួកគេត្រូវបានគោរព នៅគ្រប់កិច្ចដំណើរការនីតិវិធី[19]។ បន្ថែមលើនេះ វិធាន ២៣*ស្ទួន*ត្រូវអានរួមគ្នាជាមួយនឹងគោលការណ៍ និងគោលបំណងទូលំទូលាយរបស់តុលាការ ដូចមានចែងនៅក្នុង កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[20]។ ដូចដែលអង្គបុរេជំនុំជម្រះ បានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ "កិច្ចព្រមព្រៀងបានចែងថា គោលការណ៍ជាសារវន្តមួយក្នុងការបង្កើត អ.វ.ត.ក គឺ "ការបង្រួបបង្រួមជាតិ"។ ចំណុចនេះជាការបង្ហាញដល់ចៅក្រម ក៏ដូចជាអង្គជំនុំជម្រះនៅ អ.វ.ត.ក ឱ្យស្វែងរកទាំងការពិតស្តីពីហេតុការណ៍ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ពិសេស និងការធានាថា មានការចូលរួមប្រកបដោយអត្ថន័យ របស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ"[21]។ ជាការពិត អង្គបុរេជំនុំជម្រះបានសម្រេចស្របគ្នាថា "ការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងដំណើរការនីតិវិធី គឺជាការទទួលស្គាល់ការបន្ត ការបង្រួបបង្រួមជាតិ"[22]។

---

[19] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[20] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង")។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បូកបញ្ចូលជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកត/១០០៣/០០៦) ("ច្បាប់ អ.វ.ត.ក")។

[21] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥ (ដកស្រង់បុព្វកថានៃកិច្ចព្រមព្រៀង)។

[22] សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ឯកសារ **C11/53** ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។

11. ចំណុចទីពីរ អង្គបុរេជំនុំជម្រះគួរបញ្ជាក់បំភ្លឺ អំពីឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ ដោយសារថាសហចៅក្រមស៊ើបអង្កេត មានការខ្វែងយោបល់គ្នាលើយុត្តាធិការ និងលទ្ធផលនៃការប្រព្រឹត្តខុសគ្នា លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

12. ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន បង្កើតឱ្យមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីរប្រភេទ៖ (១) អ្នកដាក់ពាក្យសុំដែលត្រូវបានទទួលយក ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងពុំបានពិនិត្យដោយសហចៅក្រមស៊ើបអង្កេតជាតិ[23] និង (២) អ្នកដាក់ពាក្យសុំដែលត្រូវបានច្រានចោលដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងពុំបានពិនិត្យដោយ សហចៅក្រមស៊ើបអង្កេតជាតិ[24]។ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតជាតិ បដិសេធមិនពិនិត្យលើពាក្យសុំ ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ទើបសហចៅក្រមស៊ើបអង្កេតទាំងពីរ ពុំមានការព្រមព្រៀងគ្នាលើអង្គសេចក្តី ពាក់ព័ន្ធនឹងមូលដ្ឋានសម្រាប់ភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤។

13. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមរម្លឹកថា អនុលោមតាមវិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវទទួលបានសច្ចធារណ៍ នៃភាពអាចទទួលយកបាន "លើកលែង និងលុះត្រាតែ" ច្រានចោលជាស្ថាពរពីសហចៅក្រមស៊ើបអង្កេត[25]។ និយាយជាទូទៅជាងនេះ ការពិចារណាលើបញ្ហាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបកស្រាយស្របតាមកម្មវត្ថុ បរិបទ និងគោលបំណងនៃការចូលរួម របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលតម្រូវឱ្យតុលាការ "យកចិត្តទុកដាក់ពិសេស និងការធានាថា មានការចូលរួមប្រកបដោយអត្ថន័យ របស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម

---

[23] សំណុំរឿង ០០៤ ឯកសារ **D384.1** ឧបសម្ព័ន្ធ ក៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[24] សំណុំរឿង ០០៤ ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានទទួលស្គាល់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[25] វិធាន ២៣*ស្ទួន* (២) ("[...] សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍សង្ខេបទៅអង្គបុរេជំនុំជម្រះដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត។ បណ្តឹងឧទ្ធរណ៍សង្ខេបនេះ មិនផ្អាកដំណើរការនីតិវិធីទេ។ លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន")។

ដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ"[26]។ អាស្រ័យហេតុនេះ ភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គួរបានជាប្រយោជន៍ដល់ភាពអាចទទួលយកបាននៃពាក្យសុំនេះ។

14. អង្គបុរេជំនុំជម្រះគួរបញ្ជាក់ថា អ្នកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្រភេទទី១ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារគោលការណ៍សច្ចធារណ៍នៃភាពអាចទទួលយកបាន និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានសម្រេចទទួលយកពួកគេ ជាដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា សច្ចធារណ៍នៃភាពអាចទទួលយកបាននេះ បន្តអនុវត្តចំពោះគ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ "លើកលែង និងលុះត្រាតែ" មានសេចក្តីសម្រេចភាគច្រើនលើសលប់ រួមជាមួយនឹងសំអាងហេតុពីអង្គបុរេជំនុំជម្រះ បង្ហាញផ្ទុយពីនេះ។

15. ស្រដៀងគ្នានេះដែរ អង្គបុរេជំនុំជម្រះគួរសម្រេចថា សច្ចធារណ៍នៃភាពអាចទទួលយកបាន ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចជំនួសដោយសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតតែម្នាក់នោះទេ។ ជាលទ្ធផល អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ប្រភេទទី២ ដែលត្រូវបានច្រានចោលដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយពុំបានទទួលពិនិត្យដោយ សហចៅក្រមស៊ើបអង្កេតជាតិ គួរបន្តអនុវត្តសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី "លើកលែង និងលុះត្រាតែ" មានសេចក្តីសម្រេចភាគច្រើនលើសលប់ រួមជាមួយនឹងសំអាងហេតុពី អង្គបុរេជំនុំជម្រះបង្ហាញផ្ទុយពីនេះ។

16. ជាជម្រើសមួយទៀត ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចច្រានចោលពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយឯកតោភាគីបាននោះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមសន្និដ្ឋានថា ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន មានកំហុសអង្គច្បាប់ និងអង្គហេតុ ដូចបានកំណត់នៅក្នុងសារណាចម្បងៗខាងក្រោម។

[26] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។

## V. សារណាចម្លង

17. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់និងអង្គហេតុ យ៉ាងច្បាស់ក្រឡែត ដោយសារច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ចំណុចទី១ ទោះបីការពិតបង្ហាញថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានអនុវត្ត នៅទូទាំងប្រទេសក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់ព្រំដែនដោយខុសច្បាប់ លើភាពអាចទទួលយកបាននៃ ដើមបណ្តឹងរដ្ឋប្បវេណី ដោយកំណត់ជនរងគ្រោះ នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលអនុវត្តនៅទូទាំងប្រទេស (សហឧក្រិដ្ឋកម្មរួម ក) ផ្តាច់មុខចំពោះតែឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងនៅក្នុងភូមិភាគពាយ័ព្យ[27]។ ការធ្វើដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំអើពើការចោទប្រកាន់ថា យឹម ទិត្យ បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម នៅក្នុងក្របខណ្ឌជាតិ (JCE) និងបានបកស្រាយមិនត្រឹមត្រូវ លើសច្ចធារណ៍នៃព្យសនកម្មជាសមូហភាព ដែលពង្រីករហូតដល់គ្រប់សមាជិកនៃក្រុមគោលដៅ ដោយមិនខ្វល់ពីទីតាំងពួកគេឡើយ។ ការពិតដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានកម្រិតកំណត់វិសាលភាពភូមិសាស្ត្រ នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ទាក់ទងការលប់បំបាត់ខ្មែរក្រោម(សហឧក្រិដ្ឋ

[27] សូមមើល ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០១៦ (ប្រើប្រាស់ពាក្យបច្ចេកទេស “JCE A” និង “JCE B”)។ សូមមើលផងដែរ ដីកាស្តីពីភាពអាចទទួលយកបាន នៅត្រង់ កថាខណ្ឌ ៣៧ (បញ្ជាក់លម្អិតអំពី គោលនយោបាយពាក់ព័ន្ធទាំងបួន សម្រាប់ភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ជនរងគ្រោះនៅក្នុងភូមិភាគពាយ័ព្យ៖ ១) ការបង្កើតនិងដំណើរការ សហករណ៍និងការដ្ឋាន ដែលបានអនុវត្តតាមរយៈ ការធ្វើឲ្យប្រជាជនក្លាយជាទាសករ ២) ការដាក់បទបញ្ញាលើការរៀបអាពាហ៍ពិពាហ៍ ដែលបានអនុវត្ត ជាអាទិ៍ តាមរយៈការរៀបអាពាហ៍ពិពាហ៍ ឲ្យអ្នករស់នៅភូមិភាគពាយ័ព្យដោយបង្ខំ ៣) ការកសាង “សមាសភាពមិនល្អ” តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង ពលកម្មដោយបង្ខំ និងការដាក់ឲ្យស្ថិតក្នុង ស្ថានភាពអមនុស្សធម៌ ឬការសម្លាប់ “ខ្មាំង” និង “សមាសភាពមិនល្អ” ទាំងក្នុងជួរ ប.ក.ក ទាំងនៅក្រៅជួរ ប.ក.ក និង ៤) ការដាក់គោលដៅលើក្រុមជាក់លាក់។ ដីកាស្តីពីភាពអាចទទួលយកបាន ក៏បានរៀបរាប់ពីប្រភេទផ្សេងគ្នាទាំងបី នៃអ្នកដាក់ពាក្យសុំ ដែលអាចបំពេញបានតាម លក្ខខណ្ឌតម្រូវទំនាក់ទំនងហេតុនិងផល៖ ១) ប្រភេទទី១គឺ អ្នកដាក់ពាក្យសុំ ដែលបានទទួលរងព្យសនកម្ម ដោយសារផែនការរួមទូទាំងប្រទេស ដេលបានដាក់ជាបទចោទ អនុវត្តយ៉ាងហោចណាស់ពីឆ្នាំ១៩៧៦ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ (JCE B), ២) អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមឧក្រិដ្ឋកម្មខាងក្រោមនេះ ដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ យ៉ាងហោចណាស់រវាង ខែកញ្ញា–តុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩, ៣) អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមឧក្រិដ្ឋកម្មខាងក្រោមនេះ ដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីកន្លែងសម្លាប់មនុស្សភូមិព្រេល ទីកន្លែងសម្លាប់មនុស្សវត្តអង្គញជី ទីកន្លែងសម្លាប់មនុស្សភូមិព្រៃស្លែង ឬព្រៃសុខុន ទីកន្លែងសម្លាប់មនុស្សវត្តអង្គសិរីមុនី)។ ដីកាស្តីពីភាពអាចទទួលយកបាន នៅត្រង់ កថាខណ្ឌ ៣៨។

កម្មវិធី ខ)[28] បានបង្ហាញបន្ថែមពីលក្ខណៈ នៃគោលនយោបាយសហឧក្រិដ្ឋកម្មរួមទាំងអស់នេះ នៅក្នុងក្របខណ្ឌជាតិ ជាពិសេសដោយសារតែការណ៍នេះ ទាក់ទងជាមួយក្រុមឬសហគមន៍គោលដៅ។ ចំណុចទី២ ដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន មានកំហុសដោយសារបានដកចេញអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលធ្លាប់ទទួលរងព្យសនកម្ម នៅតាមទីតាំងឧក្រិដ្ឋកម្ម ដែលដំបូងជាផ្នែកមួយនៃ ការស៊ើបអង្កេតលើសំណុំរឿង ០០៤ ហើយក្រោយមកត្រូវបានដកចេញ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង។ ដូចបានបង្ហាញលម្អិតនៅក្នុងមូលដ្ឋានទី៣ និងមូលដ្ឋានទី៤ នៃបណ្ដឹងឧទ្ធរណ៍ ដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន ក៏ខកខានមិនបានបង្ហាញ សេចក្ដីសម្រេចដែលមានសំអាងហេតុ ចំពោះការច្រានចោល ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងមានកំហុសនៅក្នុងការច្រានចោល អ្នកដាក់ពាក្យសុំ ដោយសារខកខានមិនបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ និងមូលដ្ឋានពាក់ព័ន្ធ។ ជាចុងក្រោយ ការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០៤/១ និង០០៤/២ ពីសំណុំរឿង០០៤ មិនគួរកម្រិតកំណត់ លើភាពអាចទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីឡើយ (មូលដ្ឋានទី៥)។

**ក. មូលដ្ឋានទី១ នៃបណ្ដឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសម្រេចថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនង សម្រាប់សហឧក្រិដ្ឋកម្មរួម ក (គោលនយោបាយបក្សក្រុមមួយនីស្តទាំងបួន) អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) បានបំពេញដោយជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅភូមិភាគពាយ័ព្យតែប៉ុណ្ណោះ**

18. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់និងអង្គហេតុ ដោយសារខកខានមិនបានសម្រេចថា ជនរងគ្រោះនៃគោលនយោបាយទូទាំងប្រទេស ដែលស្ថិតនៅក្រៅភូមិភាគពាយ័ព្យ ក៏ទទួលរងពន្យសនកម្មដោយផ្ទាល់ ដោយសារលទ្ធផលនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់លើ យឹម ទិត្យ[29]។ សេចក្ដីសម្រេចកម្រិតភាពអាចទទួលយកបាន នៃដើមបណ្ដឹងរដ្ឋប្បវេណី ត្រឹមឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅភូមិភាគពាយ័ព្យ ពុំស៊ីសង្វាក់គ្នាជាមួយនឹង ការបកស្រាយរបស់អង្គបុរេជំនុំជម្រះ លើលក្ខខណ្ឌចំណងទាក់ទង រវាងជនរងគ្រោះ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដូចមានចែងនៅក្នុងវិធាន ២៣*ស្ទួន*(១)(ខ)។

[28] ដីកាស្ដីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៨។

[29] ដីកាសម្រេចស្ដីពីភាពអាចអាចទទួលយកបាន នៅត្រង់កថាខណ្ឌ ៣៧។

19. វិធាន ២៣*ស្ទួន*(១)(ខ) ទាមទារលក្ខខណ្ឌថា អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញ "ព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារ ឬ ផ្លូវចិត្ត" ដែលកើតចេញដោយសារ "លទ្ធផលផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់ លើជនត្រូវចោទ"[30]។ នៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលស្គាល់យុត្តិសាស្ត្ររបស់ អង្គបុរេជំនុំជម្រះថា លក្ខខណ្ឌចំណងហេតុនិងបច្ច័យ គួរត្រូវបកស្រាយ "ក្នុងន័យទូលាយ" ដោយធ្វើយ៉ាងណាវាគួរអនុញ្ញាត "ឱ្យទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលការចោទប្រកាន់អំពី ព្យសនកម្មរបស់ពួកគាត់ មិនចាំបាច់ទាល់តែកើតឡើងពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅទីតាំង ដែលបានកំណត់ក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់សហព្រះរាជអាជ្ញា ឬ នៅក្នុងដីកាដំណោះស្រាយនោះទេ"[31]។ ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន ខកខានមិនបានគោរពតាម យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ លើបញ្ហានេះ ដោយបានបដិសេធឋានៈរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងអនុលោមតាម គោលនយោបាយសម្របសម្រួលថ្នាក់ជាតិ អនុវត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម (JCE)។ ស្រដៀងគ្នានេះដែរ ដីកាស្តីពីភាពអាចទទួលយកបាន ខកខានមិនបានអនុវត្តគោលការណ៍ របស់អង្គបុរេជំនុំជម្រះ ស្តីពីព្យសនកម្មជាសមូហភាព ដែលពង្រីកឋានៈដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់សមាជិកនៃក្រុមគោលដៅ ឬ សហគមន៍ដូចគ្នា ដោយមិនគិតពីទីតាំងរបស់ពួកគេ។ ចំណុចចុងក្រោយ ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន មើលរំលងដោយប្រយោល អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្ម ពីគោលនយោបាយ និងឧក្រិដ្ឋកម្មដែលអនុវត្ត*នៅក្នុង* ទីតាំងឧក្រិដ្ឋកម្មនិងភូមិភាគ ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

**១. អង្គបុរេជំនុំជម្រះ គួរទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះជនរងគ្រោះនៃគោលនយោបាយ និងឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ដែលត្រូវបានអនុវត្តនៅទូ**

[30] វិធាន ២៣*ស្ទួន*(១)(ខ)(ការគូសបញ្ជាក់បន្ថែម)។

[31] ដីកាសម្រេចស្តីពីភាពអាចអាចទទួលយកបាន នៅត្រង់កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤៩, ៦៦, ៦៨-៦៩, ៧២, ៧៧។

**ទាំងកម្ពុជា ជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម មិនមែនត្រឹមតែនៅក្នុងតំបន់ដែលបានកំណត់ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាននោះឡើយ។**

20. ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន មិនអើពើចំពោះសេចក្តីសម្រេចពីមុន របស់អង្គបុរេជំនុំជម្រះ ស្តីពីភាពអាចទទួលយកបាន នៃដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តោតលើតែឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងភូមិភាគពាយ័ព្យ បើទោះជាការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែល យឹម ទិត្យ បានចូលរួម និងអនុវត្តគោលនយោបាយក្រោមសហឧក្រិដ្ឋកម្មរួម ដែលមានវិសាលភាពនៅទូទាំងប្រទេស។ វិធាន ២៣*ស្ទួន* (១)(ខ) ចែងច្បាស់ ហើយអង្គបុរេជំនុំជម្រះបញ្ជាក់ច្បាស់ថា លក្ខខណ្ឌចំណងទាក់ទង មិនមែនអាស្រ័យលើព្យសនកម្ម និងអង្គហេតុដែលស៊ើបអង្កេតដោយ សហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែ គឺរវាងព្យសនកម្ម និង*ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់*[32]។ ភាពខុសគ្នាដ៏សំខាន់នេះគឺ រវាងអង្គហេតុ និងអង្គច្បាប់ ដែលមានឧក្រិដ្ឋកម្ម "គឺជាការកំណត់បទចោទ ទៅលើស្ថានភាពអង្គហេតុ ដែលត្រូវបានធ្វើការស៊ើបអង្កេត"[33]។

21. នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត បានច្រានចោលដោយមិនត្រឹមត្រូវ លើពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបានកំណត់លក្ខខណ្ឌដោយមានកំហុសថា អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ចំណង ព្យសនកម្មរបស់ពួកគេ ជាមួយព្រឹត្តិការណ៍អង្គ

---

[32] វិធាន ២៣*ស្ទួន*(១)(ខ)(ការគូសបញ្ជាក់បន្ថែម)។ សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤៩, ៦៦, ៦៨-៦៩, ៧២, ៧៧។

[33] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ayyash និងអ្នកផ្សេងទៀត* STL-11-01/PT/PTJ, F0879 សេចក្តីសម្រេចទី៤ ស្តីពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ១៥ (សម្រេចថា លក្ខខណ្ឌចំណងរវាងហេតុ និងបច្ច័យ ស្ថិតនៅត្រង់ "ព្យសនកម្មដែលបានចោទប្រកាន់ ជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ជាក់លាក់នៅក្នុងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ" ហើយបានពន្យល់ថា "ការអានបែបនេះផ្តល់លក្ខណៈតាមផ្លូវច្បាប់ចំពោះដែនកំណត់នៃធាតុផ្សំហេតុ និងបច្ច័យ ដូច្នេះ វាផ្តល់ភាពកាន់តែជាក់លាក់ និងរឹងមាំ" ដល់ដំណើរការចូលរួមរបស់ជនរងគ្រោះ)។

ហេតុ ដែលបានស៊ើបអង្កេត ដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ[34]។ អង្គបុរេជំនុំជម្រះបាន កត់សម្គាល់ថា "បើទោះបីជាអង្គហេតុដែលត្រូវស៊ើបអង្កេត កំណត់ត្រឹមតែទៅលើតំបន់ ឬ ទីតាំង ឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ [...] បានរួមបញ្ចូលនូវឧក្រិដ្ឋកម្ម ដែលតំណាងឲ្យអំពើឃោរឃៅ ជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់ថា [...] បានធ្វើឡើងរួមគ្នាក្នុងពេលអនុវត្ត សហឧក្រិដ្ឋកម្មរួម [...] ប្រឆាំងនឹងប្រជាជន និង "នៅទូទាំងប្រទេស""[35]។ អង្គបុរេជំនុំជម្រះបានសម្រេចថា "វាគឺជាការកំណត់បទចោទ ទៅលើស្ថានភាពអង្គហេតុ ដែលត្រូវធ្វើការស៊ើបអង្កេត [ពោលគឺ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់] ហើយមិនមែនជាស្ថានភាពអង្គហេតុ ដែលត្រូវធ្វើការស៊ើបអង្កេតនោះទេ ដែល [សហចៅក្រមស៊ើបអង្កេត] គួរធ្វើការពិចារណា"[36]។

22. នៅក្នុងករណីដែលដីកាដំណោះស្រាយសម្រេចថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល មានលក្ខណៈទូលំទូលាយ ឬ ជាប្រព័ន្ធ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី "មិនចាំបាច់ត្រូវបង្ហាញពីទំនាក់ទំនង រវាងព្យសនកម្មរបស់ខ្លួន ទៅនឹងទីតាំងឧក្រិដ្ឋកម្មតែមួយ ឬ ទីតាំងឧក្រិដ្ឋកម្មនានា ដែលមានរៀបរាប់" នៅក្នុងដីកាដំណោះស្រាយ ជាពិសេសនៅពេល "បទឧក្រិដ្ឋទាំងនោះ និងគោលនយោបាយជាមូលដ្ឋានរបស់ខ្មែរក្រហម បានបង្កើតជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា"[37]។ អ្វីដែលគួរកត់សម្គាល់ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា "ការទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងទិដ្ឋភាពនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំ គួរ [...] សំដៅដល់បរិបទដែលឆ្លើយតបទៅនឹង សកម្មភាពដែលប្រព្រឹត្តយ៉ាងទូលំ

[34] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។

[35] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២ (សេចក្ដីយោងខាងក្នុងត្រូវបានលុបចោល)។

[36] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។

[37] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧២ (សេចក្ដីយោងខាងក្នុងត្រូវបានលុបចោល)។

ទូលាយ និងជាប្រព័ន្ធ ដែលកើតចេញពីការអនុវត្ត នូវគោលនយោបាយទាំងនេះនៅទូទាំងប្រទេស ដែលក្នុងនោះការទទួលខុសត្រូវជាលក្ខណៈបុគ្គល ដែលបានចោទប្រកាន់លើជនជាប់ចោទម្នាក់ៗ គួរធ្វើជាលក្ខណៈរួមវិញ ដោយសារមានការចោទប្រកាន់ ពីការធ្វើសកម្មភាពរួមគ្នាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម”[38]។

23. ជំហររបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០២ អនុវត្តក្នុងអានុភាពស្មើគ្នា នៅក្នុងសំណុំរឿង ០០៤។ យោងតាមដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម យឹម ទិត្យ បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម នៅកម្រិតទូទាំងប្រទេស ដែលគោលបំណងរបស់វាគឺ អនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅទូទាំងប្រទេស គឺលើសពីភូមិភាគពាយ័ព្យទៅទៀត[39]។ បក្សកុម្មុយនីស្តកម្ពុជាបន្តរក្សា ប្រព័ន្ធដែលមានការរៀបចំត្រឹមត្រូវ សម្រាប់អនុវត្តគោលនយោបាយថ្នាក់ជាតិ តាមរយៈបណ្ដាញសហគ្រាសនៅថ្នាក់តំបន់ ដែលរួមបញ្ចូលតំបន់ក្រោមបញ្ជារបស់ យឹម ទិត្យ ផងដែរ។ ប្រតិបត្តិការទាំងមូលត្រូវបានរៀបចំឡើង ដើម្បីជម្រុញ*គោលបំណងជាតិ*នៃការកសាងសង្គមកម្ពុជាទាំងមូលឡើងវិញ[40]។ ដូចដែលបានចោទប្រកាន់នៅក្នុង ដីកាដំណោះស្រាយ

---

[38] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧៨។ អ្វីដែលគួរឲ្យកត់សម្គាល់ ជនជាប់ចោទអាចត្រូវបានចាប់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) “ទោះជាការចូលរួមចំណែកជាដុំកំភួនរបស់គាត់ចំពោះសហឧក្រិដ្ឋកម្មនោះ បានកើតឡើងនៅក្នុងតំបន់ភូមិសាស្ត្រតូចមួយជាងនេះក៏ដោយ” ឲ្យតែ “គាត់បានដឹងអំពីគោលបំណងទូលំទូលាយនៃផែនការរួមនោះ”។ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Sesay, Kallon និង Gbao* SCSL-04-15-T សាលក្រម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២៦២។

[39] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០១៦ (“យឹម ទិត្យ... និងកម្មាភិបាលជាទីទុកចិត្តពីភូមិភាគនិរតី បានធ្វើប្រតិបត្តិការនៅភូមិភាគពាយ័ព្យ នៃកម្ពុជាប្រជាធិបតេយ្យ ដើម្បីអនុវត្តគោលនយោបាយនានារបស់ ប.ក.ក ស្ដីពីការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ បទប្បញ្ញត្តិអាពាហ៍ពិពាហ៍ ដែលត្រូវបានអនុវត្ត ជាអាទិ៍ “តាមរយៈអាពាហ៍ពិពាហ៍ប្រជាជនដោយបង្ខំ ការអប់រំអ្នកដែលហៅថា “សមាសធាតុមិនល្អ” និងការសម្លាប់ “ខ្មាំង” និង “សមាសធាតុមិនល្អ” ទាំងក្នុងជួរ និងក្រៅជួរ ប.ក.ក ព្រមទាំងការកំណត់គោលដៅក្រុមជាក់លាក់” ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ កថាខណ្ឌ ៦ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ កថាខណ្ឌ១៤។

[40] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ២៧៦ (“បក្សកុម្មុយនីស្តកម្ពុជា បានព្យាយាមផ្លាស់ប្ដូរប្រទេសកម្ពុជា ពីសេដ្ឋកិច្ចទីផ្សារ ទៅជារដ្ឋសង្គមនិយមទីពឹងខ្លួនឯង ផ្អែកលើសេដ្ឋកិច្ចកសិកម្ម។ គោលដៅនេះត្រូវសម្រេចតាមរយៈ វិធានការមួយចំនួនសំខាន់បំផុតត្រូវបង្កើតសហករណ៍ និងការដ្ឋាន នៅទូទាំងប្រទេសកម្ពុជា និងការផ្លាស់ទីលំនៅដោយបង្ខំ ចំពោះប្រជាជនទាំងមូល

របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "យឹម ទិត្យ គឺជាមនុស្សចម្បងម្នាក់ ដែលមានការទទួលខុសត្រូវចំពោះ ការអនុវត្តគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងតំបន់ដែលស្ថិតនៅក្រោម ការទទួលខុសត្រូវរបស់គាត់ ដូច្នេះគាត់បានដឹងយ៉ាងច្បាស់ថា ការអនុវត្តគោលនយោបាយទាំងបួន របស់បក្សកុម្មុយនីស្តកម្ពុជា អាចសម្រេចទៅបាន មានតែអនុវត្តតាមរយៈឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ទាំងនោះ"[41]។ យឹម ទិត្យ បានបង្ហាញនូវ "កសិណរបស់គាត់ ដែលបញ្ជាក់យ៉ាងច្បាស់អំពីការប្ដេជ្ញាចិត្តរបស់គាត់ ដើម្បីអនុវត្តផែនការនានារបស់អង្គការ"[42]។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ យឹម ទិត្យ ត្រូវបានកំណត់ឈ្មោះក្នុងចំណោម មេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះគោលនយោបាយនៅទូទាំងប្រទេសទាំងអស់នេះ[43]។ ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងគោលនយោបាយកម្រិតជាតិ នៃសហឧក្រិដ្ឋកម្មរួមនេះ ត្រូវបានគូសបញ្ជាក់ដោយការអះអាង របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា "ក្នុងឋានៈជាលេខាតាមព្រឹត្តហេតុ ឬតាមនីតិន័យរបស់ភូមិភាគ ដែលជាភូមិភាគមួយដ៏សំខាន់បំផុតជាយុទ្ធសាស្ត្រ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ [យឹម] ទិត្យ អាចក្លាយទៅជា

ដែលត្រូវធ្វើការនៅតាមសហករណ៍ និងការដ្ឋាននោះ" ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៨៧ ("គោលនយោបាយនេះ ត្រូវបានអនុញ្ញាតតាមមាត្រា ១០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលចែងថា "*សកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញ ដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្ដន្ទាទោសកម្រិតខ្ពស់បំផុត*")។ ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៩៥ ("គោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា ក្នុងការចាប់ខ្លួន និងសម្លាប់ខ្មាំង ត្រូវបានអនុវត្តឡើងក្នុងលក្ខណៈធ្ងន់ធ្ងរហួសហេតុ នៅក្នុងអំឡុង "*បោសសម្អាត*" ជាបន្តបន្ទាប់ ទៅលើជួរបក្សកុម្មុយនីស្តកម្ពុជា និងទៅលើប្រជាជនទូទៅ") ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៩៨ ("យឹម ទិត្យដើរតួនាទីស្នូល ក្នុងការអនុវត្តគោលនយោបាយ កសិកម្មនិងសេដ្ឋកិច្ច នៅភូមិភាគពាយ័ព្យ ដែលមានគោលដៅបង្កើនការផលិតនៅទូទាំងប្រទេស របស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្កើតការដ្ឋាននិងសហករណ៍") ដូចដើងទំព័រខាងលើ កថាខណ្ឌ ៣១៤ (ពន្យល់ថា "គោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍" ត្រូវបានរៀបចំឡើង "ដើម្បីសម្រេចគោលដៅ ក្នុងការបង្កើតចំនួនប្រជាជន និងកសាងគ្រួសារបរិសុទ្ធ ផ្អែកមនោគមន៍វិជ្ជា") ដូចដើងទំព័រខាងលើ កថាខណ្ឌ [redacted] ("យឹម ទិត្យ បានដឹងអំពីសកម្មភាពទាំងអស់របស់ ប.ក.ក នៅតាមតំបន់ដែលគាត់ត្រួតត្រា។ ចំណេះដឹងនេះបានទទួលតាមរយៈ ការប្រជុំ និងប្រព័ន្ធទំនាក់ទំនង និងការរាយការណ៍ ដែលគាត់បានថែរក្សាជាមួយថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់របស់គាត់")។

[41] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០២០។

[42] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០២២។

[43] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ ២១, ២៣។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីពីរ កថាខណ្ឌ ១៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបី កថាខណ្ឌ ១៤។

សមាជិករបស់គណៈមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងមហាសន្និបាតបក្សលើកទី៥"[44]។ ការចូលរួមសហការយ៉ាងជិតស្និទ្ធរបស់ យឹម ទិត្យ ជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដទៃទៀត ដូចជា តាម៉ុក ជាដើម នៅក្នុង "គោលបំណងរួមដើម្បីអនុវត្ត នៅក្នុងតំបន់ជាក់លាក់នានា នៃកម្ពុជាប្រជាធិបតេយ្យ នូវផែនការទូទាំងប្រទេសមួយ ក្នុងការកម្ទេចទាំងស្រុង ឬមួយផ្នែកនៃខ្មែរក្រោម" បានបង្ហាញកាន់តែច្បាស់ថែមទៀត ពីការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការអនុវត្តនៅទូទាំងប្រទេស នូវគោលនយោបាយសហឧក្រិដ្ឋកម្មរួម[45]។

24. ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់បន្ថែមទៀតដល់ មាស មុត ថាបានកាន់កាប់ "តួនាទីលេចធ្លោជាច្រើន នៅក្នុងអំឡុងពេលកាន់តំណែងរបស់គាត់ នៅក្នុងភូមិភាគនិរតី" ដូចជា "មេបញ្ជាការទីពីរតាមព្រឹត្តន័យទីពីររបស់ តាម៉ុក" និងជា "មនុស្សទីពីរដែលមានអំណាចជាងគេ នៅភូមិភាគពាយ័ព្យបន្ទាប់ពី តាម៉ុក"[46] យឹម ទិត្យ គឺជាប្អូនថ្លៃរបស់តាម៉ុក និងក្នុងនាម "ជាសមាជិកគ្រួសាររបស់តាម៉ុក ... បានឡើងឋានៈយ៉ាងរហ័ស" ដោយត្រូវបានតែងតាំងជាលេខាស្រុកគិរីវង្ស នៅក្នុងភូមិភាគនិរតី និងជាទូទៅគឺជា "មេបញ្ជាការទីពីររបស់ តាម៉ុក"[47]។ ដោយចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ១៩៧៧ យឹម ទិត្យ "និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំផែនការ និងបានផ្តួចផ្តើមឲ្យមានការបោសសម្អាត យ៉ាងរង្គាលមួយនៅក្នុងភូមិភាគពាយ័ព្យ ដែលចាប់ផ្តើមនៅពេលមានការមកដល់ នូវកងកម្លាំងរបស់ភូមិភាគនិរតី... នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧"[48]។ ជាទូទៅ យឹម ទិត្យ ដឹកនាំការប្រជុំតែម្នាក់ឯង និងជាមួយមេដឹកនាំដទៃទៀត ដូចជាលេខាភូមិភាគគឺតាម៉ុក ព្រមទាំងចុះពិនិត្យមើលតាមការដ្ឋាន ទៅពិនិត្យមន្ទីរសន្តិសុខ និងក្រោយមកមានសិទ្ធិអំណាច ទៅលើកងទ័ព, បញ្ហាបុគ្គលិក, គោលនយោបាយសន្តិសុខនិងសេដ្ឋកិច្ច នៅក្នុងតំបន់ដែលគាត់គ្រប់គ្រង[49]។ យឹម ទិត្យ "ជាមេដឹកនាំតាម

---

[44] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៩៥។

[45] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០១៦។ សូមមើលផងដែរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ ១១។

[46] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣២៧, ៣៨០, ៩៩៤។

[47] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៣, ៩១។

[48] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី, កថាខណ្ឌ ៩៤។

[49] ~~ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៦៤-៣៦៧, ៣៧៤~~។

ព្រឹត្តហេតុ របស់ភូមិភាគពាយ័ព្យ" រហូតដល់ខែមិថុនា ឆ្នាំ១៩៧៨ ដែលនៅពេលនោះ គាត់ "បានចូលកាន់តំណែងជាលេខាតំបន់១ របស់ភូមិភាគពាយ័ព្យ និងជាអនុលេខាគណៈភូមិភាគពាយ័ព្យ" ក្រោយពេលចាប់ខ្លួន មូល សម្បត្តិ ហៅ រស់ ញឹម អតីតលេខាភូមិភាគពាយ័ព្យ[50]។ ក្នុងតួនាទីជាលេខា យឹម ទិត្យ "មានសិទ្ធិអំណាចទៅលើ កិច្ចការស៊ីវិលនិងយោធា" ហើយ "ទទួលខុសត្រូវផ្ទាល់" ទៅលើមន្ទីរសន្តិសុខនៅភូមិភាគពាយ័ព្យ[51]។ ដោយផ្អែកលើ តួនាទីរបស់ យឹម ទិត្យ និងឥទ្ធិពលនៃសកម្មភាពរបស់គាត់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានថា "តួនាទីនិងសកម្មភាពរបស់គាត់ អាចប្រៀបធៀបបានយ៉ាងងាយ ជាមួយនឹងតួនាទីនិងសកម្មភាពរបស់ អោ អាន ឬ មាស មុត ហើយប្រាកដណាស់ក៏អាចប្រៀបធៀបបាន ជាមួយនឹងតួនាទីនិងសកម្មភាពរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែរ" ដែលជួនកាលទៀតអាចលើសច្រើនជាងនេះទៀតផង"[52]។

25. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បង្ហាញលម្អិតអំពីរបៀប ដែល យឹម ទិត្យ បានទទួលការងារអនុវត្ត គោលនយោបាយជាតិនៃ បក្សកុម្មុយនីស្តកម្ពុជា នៅថ្នាក់តំបន់ ដោយសារមុខតំណែងដឹកនាំ ដូចបានចោទប្រកាន់លើរូបគាត់ ដែលរួមមាន៖ (i) ការដាក់ប្រជាជនឱ្យទៅជាទាសករ នៅតាមសហករណ៍ ឬ ការដ្ឋានការងារដោយបង្ខំ (ii) ការអប់រំ ឬ ការកំចាត់ខ្មាំងបក្សកុម្មុយនីស្តកម្ពុជា តាមរយៈបណ្តាញមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (iii) ការកំណត់គោលដៅក្រុមជនសង្ស័យ ដូចជាជនជាតិវៀតណាម និងអ្នកជម្លៀសមកពីភូមិភាគបូព៌ា និង (iv) អាពាហ៍ពិពាហ៍ដោយបង្ខំ (ដែលជារួមគឺសហឧក្រិដ្ឋកម្មរួមក)[53]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរកឃើញថា យឹម ទិត្យ បានអនុវត្ត និងបាន "ចូលរួមចំណែកសំខាន់" នៅក្នុងគោលនយោបាយជាតិទាំងបួន[54] ព្រមទាំង

---

[50] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៩៥។

[51] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៩៦។

[52] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩៩។

[53] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ កថាខណ្ឌ ១៦-១៧, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ ២១, ២៣, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ កថាខណ្ឌ ១៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី កថាខណ្ឌ ១៤។

[54] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០២២-១០២៤ សូមមើលផងដែរ ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០១៦ (ពិពណ៌នាគោលនយោបាយជាតិទាំងបួន៖ "ការបង្កើតនិងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ" បទប្បញ្ញត្តិអាពាហ៍ពិពាហ៍ ដែលត្រូវបានអនុវត្តជាអាទិ៍ តាមរយៈអាពាហ៍ពិពាហ៍ប្រជាជនដោយបង្ខំ ការអប់រំអ្នកដែលហៅថា

សហឧក្រិដ្ឋកម្មរួមពីរបន្ថែមទៀត (១) ការបោសសម្អាតទាំងស្រុង ឬដោយផ្នែកនូវខ្មែរក្រោម (សហឧក្រិដ្ឋកម្មរួម ខ) និង (២) ជម្រុញដល់ប្រព័ន្ធនៃការធ្វើបាបនៅមន្ទីរសន្តិសុខវត្តព្រះធាតុ (សហឧក្រិដ្ឋកម្មរួម គ)[55]។

26. ទោះបីជាមានការបង្ហាញយ៉ាងច្បាស់អំពី "ទិដ្ឋភាពជារួម" នៃការទទួលខុសត្រូវរបស់ មាស មុត ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តោតសំខាន់លើតែឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងភូមិភាគពាយ័ព្យ ដើម្បីកំណត់ភាពអាចទទួលយកបាន នៃដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ជនរងគ្រោះនៃសហឧក្រិដ្ឋកម្ម ក (គោលនយោបាយទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា)។ នេះគឺជាកំហុស។ ផ្ទុយទៅវិញ ពាក់ព័ន្ធនឹងការវិភាគអំពី ភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គួរតែបានពិចារណាអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្រៅភូមិភាគពាយ័ព្យ ដែលបង្កើតបានជាផ្នែកនៃ សហឧក្រិដ្ឋកម្មថ្នាក់ជាតិ ដែល យឹម ទិត្យ ត្រូវបានចោទប្រកាន់ថាជាសមាជិកម្នាក់ដែរ។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលកម្រិតភាពអាចទទួលយកបាន នៃដើមបណ្តឹងរដ្ឋប្បវេណី តែទៅលើទីតាំងភូមិសាស្ត្រដែល យឹម ទិត្យ មានការគ្រប់គ្រងរដ្ឋបាលទាំងស្រុង មិនអាចស៊ីសង្វាក់គ្នាជាមួយនឹងសំអាងហេតុនៅក្នុងដីកាដំណោះស្រាយ របស់គាត់នោះទេ។ ដីកាស្តីពីភាពអាចទទួលយកបាន ខកខានមិនបានបង្ហាញសេចក្តីសម្រេច ដែលមានសំអាងហេតុ ចំពោះការកម្រិតភូមិសាស្ត្រ ស្តីពីភាពអាចទទួលយកបាន នៃដើមបណ្តឹងរដ្ឋប្បវេណី ដែលរារាំងសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានព័ត៌មាន និងក្នុងការទទួលបានការពិនិត្យមើល បណ្តឹងឧទ្ធរណ៍ឡើងវិញ ប្រកបដោយប្រសិទ្ធភាព។

27. ដូចបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ខ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើម បណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីគោលនយោបាយ កំណត់ជ្រើសរើស នៃសហឧក្រិដ្ឋកម្មរួម ក) និង ឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីគោលនយោបាយ កំណត់គោលដៅនៃសហឧក្រិដ្ឋកម្មរួម ក) ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរងព្យសនកម្មដោយផ្ទាល់ពីការអនុវត្ត សហឧក្រិដ្ឋកម្មថ្នាក់ជាតិ ដែល យឹម ទិត្យ ត្រូវបានចោទប្រកាន់ថាបានចូលរួម។ នៅក្នុងចំណោមអ្នកដែលត្រូវបានបដិសេធ ឋានៈជាដើមបណ្តឹងរដ្ឋ

"សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" និង "សមាសធាតុមិនល្អ" ទាំងក្នុង និងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងការកំណត់គោលដៅក្រុមជាក់លាក់")។

[55] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០១៦។

ប្បវេណី នៅក្នុងសំណុំរឿង ០០៤ រួមមានជនរងគ្រោះដែលទទួលរងព្យសនកម្ម ដោយសារផលវិបាកនៃគោលនយោបាយជាតិទាំងបួន ដែលបានអនុវត្តដើម្បីពន្លឿន ការសម្រេចផែនការឧក្រិដ្ឋរួមនៃ សហឧក្រិដ្ឋកម្មរួម (សហករណ៍និងការដ្ឋាន, ការគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍, ការកំណត់គោលដៅលើក្រុមជាក់លាក់, និងការអប់រំរៀនសូត្រ និងការសម្លាប់ខ្មាំង)។ ឧទាហរណ៍ដែលបង្ហាញ អំពីព្យសនកម្មដែលទទួលរង ដោយដើមបណ្ដឹងរដ្ឋប្បវេណី ក្រោមគោលនយោបាយជាតិទាំងអស់នោះ ហើយដែលចាត់ទុកថាមិនអាចទទួលយកបាន គឺរួមមាន៖

(១) អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី អន ដារ៉ាវុត (17-VSS-00043) មានអាយុត្រឹមប្រាំបីឆ្នាំ នៅពេលដែលគាត់និងក្រុមគ្រួសាររបស់គាត់ដែលមានគ្នាប្រាំពីរនាក់ ត្រូវបានបង្ខំឱ្យចាកចេញពីទីក្រុងកំពង់សោម ដោយយកតាមខ្លួនត្រឹមតែទ្រព្យសម្បត្តិដែលអាចយួរបាន ហើយបានឃើញភាពវឹកវរ ជំងឺដង្កាត់ និងការស្លាប់នៅតាមផ្លូវ។ ក្នុងពេលធ្វើដំណើរតាមរទេះ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសាររបស់គាត់ ត្រូវបានគេបំបែកចេញពីឪពុក ដែលជាមន្ត្រីចារកម្ម និងជាអ្នកអក្សរសាស្ត្រ ហើយពួកគាត់លែងបានឃើញឪពុកជារៀងរហូត។ នៅពេលដែលអ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់គាត់ មកដល់ទីជនបទ គ្រួសារគាត់ត្រូវបានគេចាត់ថ្នាក់ជា "ប្រជាជនថ្មី"។ សមាជិកទាំងអស់ក្នុងគ្រួសារគាត់ ត្រូវបានគេបង្ខំឱ្យធ្វើពលកម្មធ្ងន់ធ្ងរ។ អ្នកដាក់ពាក្យសុំបានទទួល ត្រឹមតែបបររាវមួយចាន សម្រាប់ហូបនៅពេលថ្ងៃត្រង់ ដូច្នេះគាត់ត្រូវស្វែងរកអ្វីផ្សេងទៀត ដើម្បីហូតនៅតាមវាលនិងក្នុងព្រៃ ក្នុងពេលដែលគាត់ឃ្វាលគោក្របី។ នៅពេលនោះអ្នកដាក់ពាក្យសុំ បានឃើញមនុស្សជាច្រើននាក់ ត្រូវបានគេវាយនឹងដំបងឈើ ឬចបហើយគេចាប់ចងយកចេញទៅ។ គាត់និងក្មេងៗផ្សេងទៀត ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារហេតុការណ៍នេះ។ សម្រាប់ពួកគេ នេះគឺជាជីវិត គាត់បានដឹងត្រឹមតែប៉ុណ្ណឹង។ បីខែបន្ទាប់មក អ្នកដាក់ពាក្យសុំត្រូវបានគេបញ្ជូន ទៅក្នុងកងចល័តកុមារ ដោយបំបែកចេញពីគ្រួសាររបស់គាត់ ត្រូវផ្លាស់ទៅនៅខ្ទមមួយ នៅក្នុងព្រៃចម្ងាយប្រមាណ ១៥ ទៅ៣០ គីឡូម៉ែត្រ (១០ ទៅ២០ម៉ៃយ៍) ពីភូមិ ហើយគាត់ត្រូវកាប់ឆ្ការព្រៃ ដើម្បីយកដីធ្វើចំការ។ ការងារគឺលំបាកខ្លាំងណាស់។ គាត់ត្រូវជួយកាត់ដើមឈើ និងគាស់គល់ពីរទៅបីដើមក្នុងមួយថ្ងៃ ហើយគាត់ត្រូវគេដុសខាត់ខួរក្បាល ដោយពាក្យឃោសនារបស់ខ្មែរក្រហម និងទទួលបានត្រឹមបបរ

ភាវពីរចានប៉ុណ្ណោះ។ អ្នកដាក់ពាក្យសុំទៅជាហើម ដោយសារខ្វះអាហារូបត្ថម្ភ ហើយជាញឹកញាប់គាត់ត្រូវខ្ជួយទិច ឬចែខាំនៅក្នុងព្រៃ។ ពេលខ្លះកម្មាភិបាលខ្មែរក្រហម ចាប់គាត់ចងនឹងដើមឈើរាប់ម៉ោង ឬរហូតដល់មួយថ្ងៃ ជាទណ្ឌកម្មដែលគាត់បានលួច របស់ហូបដែលមិនបានប្រមូលផល ដែលគេទុកចោលនៅតាមវាល។ ក្មេងៗផ្សេងទៀតនៅក្នុងកងរបស់គាត់ ត្រូវបានគេវាយដំឬសម្លាប់ នៅចំពោះមុខក្រុមក្មេងៗ ដោយមេដឹកនាំខ្មែរក្រហម ដែលចោទប្រកាន់ពួកគេថាជាខ្មាំងរដ្ឋ។ នៅក្នុងឆ្នាំ១៩៧៦ អ្នកដាក់ពាក្យសុំត្រូវបានគេបញ្ជូនចេញ ជាមួយប្រជាជនដទៃទៀតរាប់ពាន់នាក់ ពីតំបន់របស់គាត់ ទៅខេត្តកំពង់ឆ្នាំង តាមរថភ្លើងដឹកទំនិញ។ ការធ្វើដំណើរតាមរថភ្លើងយឺត ហើយចង្អៀតណែន ហើយអ្នកដាក់ពាក្យសុំនិងអ្នកធ្វើដំណើរដទៃទៀត មិនមានអាហារ ឬទឹកផឹកឡើយ ដែលធ្វើឲ្យពួកគេជាច្រើននាក់បាក់កម្លាំង វង្វេងវង្វាន់ និងស្លាប់ក្នុងពេលធ្វើដំណើរ។ នៅពេលដែលអ្នកដាក់ពាក្យសុំមកដល់ គាត់ត្រូវបានគេដាក់នៅក្នុងជំរំពលកម្មយុវជន ដែលក្នុងជំរំនោះកាន់តែធ្ងន់ធ្ងរឡើង ហើយមនុស្សជាច្រើនជាពិសេស អ្នករៀនសូត្រនិងអ្នកមាន ត្រូវបានគេសម្លាប់ចោល។ គាត់បានឃើញសាកសពពួកគេនៅតាមផ្លូវ ទៅកន្លែងធ្វើការរបស់គាត់ ឬនៅក្នុងផ្ទះដែលគេជីករាក់ៗ ហើយមានសត្វព្រៃខាំហែកសាកសពទាំងអស់នោះ។ មកដល់ត្រឹមនេះ សមាជិកគ្រួសារភាគច្រើន របស់អ្នកដាក់ពាក្យសុំ បានធ្លាក់ខ្លួនឈឺ ដោយសារអត់ឃ្លានខ្លាំងមិនអាចធ្វើដំណើរបាន និងមិនមានថាមពល។ ចំពោះគាត់ស្ថានភាពបែបនេះគឺ ពួកគេហាក់ដូចជារង់ចាំ គេយកទៅសម្លាប់ ឬស្លាប់ដោយគ្រុនចាញ់ ឬជំងឺដទៃផ្សេងទៀត។ នៅក្នុងពេល៦ទៅ១២ខែក្រោយ ជីតា បងប្អូនស្រី និងម្តាយរបស់អ្នកដាក់ពាក្យសុំ បានស្លាប់ដោយសារអត់អាហារ។ អ្នកដាក់ពាក្យសុំជឿថា គាត់អាចនៅរស់រានមានជីវិតដោយសារតែគាត់ត្រូវបានបញ្ជូនទៅកាប់ឆ្កាដី ដែលនៅទីនោះគាត់អាចស្វែងរកអ្វីហូបបន្ថែម លើរបបអាហាររបស់គាត់ គឺអ្វីដែលគាត់អាចរកបានតាមធម្មជាតិ។ ទោះបីជាបែបនេះក្តី កុមារខ្លះផ្សេងទៀត ដែលធ្វើការនៅក្នុងកងរបស់គាត់ ធ្លាក់ខ្លួនខ្សោយខ្លាំង ហើយដួលស្លាប់ពេលកំពុងធ្វើការ។ នៅទីបញ្ចប់ ការដ្ឋានការងារដ៏ធំរបស់គាត់ ដែលមានមនុស្សរាប់ពាន់នាក់ បានធ្លាក់ចុះនៅសល់ត្រឹមរាប់រយនាក់ ហើយអ្នកដាក់ពាក្យសុំ ត្រូវបានចាត់តាំងឲ្យជួយសែងសាកសព។ នៅក្នុងរបបខ្មែរ

ក្រហម គឺមានតែអ្នកដាក់ពាក្យសុំ និងបងប្អូនប្រុសគាត់តែម្នាក់ប៉ុណ្ណោះ ដែលនៅរស់។ ចុងក្រោយពួកគេបានរត់គេចចេញទៅ ជំរុំជនភៀសខ្លួន ប៉ុន្តែពួកគេរស់នៅដោយលំបាក ក្នុងនាមជាក្មេងកំព្រា[56]។

(២) នៅក្នុងរបប ប៉ុល ពត សេវ ហៀម (13-VSS-00282) និងក្រុមគ្រួសាររបស់គាត់ រស់នៅនិងធ្វើការនៅសហករណ៍ ម-៤ ដែលស្ថិតនៅក្នុងភូមិតាំងសេ ឃុំមុំបួន ស្រុក២១ ខេត្តរតនគិរី។ នៅក្នុងឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហម ត្រូវបានបញ្ជូនឱ្យទៅរកនារី១៣នាក់ ដើម្បីយកទៅរៀបការ។ ពួកកងទ័ពទាំងនោះ ព្យាយាមបង្ខំប្អូនស្រីរបស់គាត់ឈ្មោះ សេវ ដ្វាន់ (អាយុ១៨ឆ្នាំ) និង សេវ បើញ (អាយុ១៦ឆ្នាំ) ឱ្យរៀបការជាមួយបុរស ដែលពួកគេមិនដែលស្គាល់។ ប្អូនស្រីទាំងពីរនាក់របស់គាត់ បានប្រកែកមិនព្រមរៀបការ ហើយពួកគាត់ត្រូវបានគេចាប់ខ្លួន ហើយយកទៅទុកនៅផ្ទះមួយ ដែលនៅទីនោះពួកគាត់ត្រូវបានគេចាប់រំលោភ ហើយសម្លាប់ចោល។ អ្នកដទៃផ្សេងទៀតដែលមិនប្រកែក ត្រូវបានបង្ខំឱ្យរៀបការ នៅកងវរៈសេនាធំលេខ ៣ នៃកងពលធំ ៨០១ ដែលស្ថិតនៅជិតទន្លេតាបុក ស្រុកតាវែង ខេត្តរតនគិរី។ ប្រហែលដប់ថ្ងៃក្រោយ កម្មាភិបាលខ្មែរក្រហម បានមកសហករណ៍ម-៤ ហើយប្រាប់ដល់ប្រជាជននៅទីនោះថា នារីណាដែលប្រកែកមិនព្រមរៀបការតាមបញ្ជារបស់អង្គការ នឹងត្រូវសម្លាប់។ ក្រោយមកនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ខ្មែរក្រហមបានព្យាយាមបង្ខំប្អូនប្រុស អ្នកដាក់ពាក្យសុំ ដែលមានឈ្មោះ សេវ យើញ ឱ្យរៀបការជាមួយនារីម្នាក់ ដែលគាត់មិនដែលបានជួបពីមុនមក ប៉ុន្តែគាត់បានបដិសេធ ហើយត្រូវបានគេចាប់ខ្លួន នៅសហករណ៍ម-៤ និងយកទៅសម្លាប់។ ឪពុក និងពូរបស់អ្នកដាក់ពាក្យសុំ ត្រូវបានគេសម្លាប់ទាំងពីរនាក់ នៅក្នុងឆ្នាំ១៩៧៨ ដោយចោទប្រកាន់ថាពួកគេជា “អាយ៉ងយួន”។ ឪពុករបស់អ្នកដាក់ពាក្យសុំ ប្រកែកមិនព្រមសារភាព តាមការចោទប្រកាន់ទាំងអស់នោះ ហើយត្រូវបានគេវាយដំជាដំណំ ធ្វើឱ្យបាក់ចង្កេះរបស់គាត់ ហើយត្រូវបានគេចងដូចសត្វធាតុ ហើយសែងយកទៅទីកន្លែងមួយ ដែលគាត់មិនដឹង ហើយចាប់ពីពេលនោះមក គឺ

[56] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/1982** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អន ដារ៉ារុត ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨ នៅត្រង់ 01425448-50។

លែងឃើញគាត់ជារៀងរហូត។ បន្ទាប់ពីពេលនោះមក អ្នកដាក់ពាក្យសុំបានរស់នៅក្នុង "ភាពភ័យខ្លាចរងទុក្ខវេទនាជាទីបំផុត" ជាមួយម្ដាយនិងប្អូនប្រុសរបស់គាត់ រហូតដល់ថ្ងៃរំដោះ[57]។

(៣) នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានផ្លាស់ទីលំនៅ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន ហឿន (11-VSS-00094) យ៉ាងហោចណាស់ទៅកាន់ប្រាំទីតាំងផ្សេងៗគ្នា នៅក្នុងខេត្តកំពង់ចាម ដែលនៅទីនោះគាត់ត្រូវធ្វើការយ៉ាងយូរ ចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង៨យប់ ដោយធ្វើការកសាងទំនប់ប្រឡាយ ហើយអ្នកយាមរបស់ខ្មែរក្រហម ផ្ដល់ដល់គាត់និងកម្មកររងទៃទៀត ត្រឹមតែបបររាវសម្រាប់ហូបប៉ុណ្ណោះ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ ឪពុករបស់គាត់ឈ្មោះ ប៉ែន ចន ត្រូវបានគេចាប់ខ្លួនដោយចោទប្រកាន់ថា គាត់បានផ្ដល់ស្រូវដល់ពួកខ្មែរស (ចលនា "ក្រមាស" របស់ខ្មែរក្រោម) ។ ពីដំបូងឪពុករបស់គាត់ត្រូវបានឃុំខ្លួន នៅមន្ទីរសន្តិសុខស្រុក នៅឯស្រុកព្រៃឈរ ខេត្តកំពង់ចាម ហើយត្រូវបានគេបង្ខំឲ្យកសាងទំនប់និងជីកប្រឡាយ ប៉ុន្តែបន្ទាប់ពីប្រាប់ប្អូនស្រីរបស់អ្នកដាក់ពាក្យសុំថា គាត់ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខតំបន់រួចមក ឪពុករបស់អ្នកដាក់ពាក្យសុំបានបាត់ខ្លួន ហើយក៏សន្មតថាគេសម្លាប់ទៅហើយ។ ដូចគ្នានេះដែរ ពូរបស់អ្នកដាក់ពាក្យសុំបួននាក់មានឈ្មោះ ហាង ផាត ហាង យយ ហាង ឆាត និងហាង កាន ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរសន្តិសុខទួលបេង នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយបន្ទាប់មកត្រូវបានបញ្ជូន ទៅមន្ទីរសន្តិសុខមួយផ្សេងទៀត នៅក្នុងស្រុកព្រៃឈខេត្តកំពង់ចាម ហើយនៅទីនោះពួកគាត់ត្រូវបានគេសម្លាប់ ដោយចោទប្រកាន់ថាក្បត់អង្គការ ហើយចូលជាមួយពួកខ្មែរស[58]។

[57] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/1116**, ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេវ ហៀម ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ នៅត្រង់ 01026075-01026086។

[58] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/178** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ែន ហឿន ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ នៅត្រង់ 00563743-44, 00563748-49។

28. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកំណត់អត្តសញ្ញាណ នៅក្នុងឧបសម្ព័ន្ធ ខ (ព្យសនកម្មចំពោះ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីគោលនយោបាយ កំណត់ជ្រើសរើស នៃសហឧក្រិដ្ឋកម្មរួម ក) និង ឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីគោលនយោបាយ កំណត់គោលដៅ នៃសហឧក្រិដ្ឋកម្មរួម ក) បានទទួលរងព្យសនកម្មដោយផ្ទាល់ ពីការអនុវត្តសហឧក្រិដ្ឋកម្មថ្នាក់ជាតិ ដែល យឹម ទិត្យ ត្រូវបានចោទប្រកាន់ថាបានចូលរួម។ យោងតាមសំអាងហេតុខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ទទួលយកអ្នកដាក់ពាក្យសុំទាំងនេះ ជាដើមបណ្តឹងរដ្ឋប្បវេណី។

## ២. អង្គបុរេជំនុំជម្រះគួរតែទទួលយកជនរងគ្រោះនៃក្រុមគោលដៅជាក់លាក់ ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់បានទទួលរងព្យសនកម្មរួម ដែលបានពង្រីកហួសពីតំបន់ ដែលបានកំណត់អត្តសញ្ញាណ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន

29. ដីកាស្តីពីភាពអាចទទួលយកបាន ក៏មានកំហុសឆ្គងផងដែរ ក្នុងការកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលរស់នៅក្នុងតំបន់ដែល យឹម ទិត្យ មានសិទ្ធិអំណាចគ្រប់គ្រងរដ្ឋបាល ដោយហេតុថាសមាជិកនៃសហគមន៍ ឬក្រុមគោលដៅជាក់លាក់ ដែលរស់នៅក្រៅតំបន់ទាំងអស់នេះ ក៏បានទទួលរងនូវព្យសនកម្ម ពីការខូចខាតជាសមូហភាពផងដែរ។

30. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា “សច្ចធារនៃការខូចខាតជាសមូហភាព” ដែលពង្រីកលើសពីសមាជិកនៃក្រុម ឬសហគមន៍ ដែលត្រូវបានធ្វើទុក្ខបុកម្នេញដូចគ្នា នៅពេលដែលឧក្រិដ្ឋកម្មសាហាវយង់ឃ្នង់ ជាទ្រង់ទ្រាយធំ ដូចជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានចោទប្រកាន់[59]។ តាមរយៈការសន្និតនេះ “ករណីដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថាគាត់គឺជាសមាជិកនៃក្រុមឬសហគមន៍គោលដៅតែមួយ ជាមួយនិងជនរងគ្រោះផ្ទាល់ គឺព្យសនកម្មអាចជាព្យសនកម្មផ្លូវចិត្ត ដែលជនរងគ្រោះដោយប្រយោលបានទទួលរង ដែលព្យសនកម្មនេះ កើតចេញពីព្យសនកម្មដែលជនរងគ្រោះ

[59] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ៨៣ ដល់៩៣។

ផ្ទាល់បានទទួលរង"[60]។ អង្គបុរេជំនុំជម្រះ បានផ្តល់សំអាងហេតុថា "នៅពេលជនរងគ្រោះដោយប្រយោល ជាសមាជិកនៃក្រុមមនុស្ស ឬសហគមន៍ណាមួយ ដែលក្លាយជាគោលដៅ នៃការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជានោះ មិនមានភាពខុសគ្នារវាងអ្វី ដែលបានកើតឡើងចំពោះបុគ្គលម្នាក់ៗ និងអ្វីដែលបានកើតឡើងជារួមឡើយ"[61]។ អង្គបុរេជំនុំជម្រះក៏យល់ឃើញថែមទៀតថា "វាជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាត ដែលបង្កដោយអំពីសាហាវឃោឃៅជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល [...]។ អំពើសាហាវឃោឃៅជាទ្រង់ទ្រាយធំ ដែលជាផលវិបាកនៃការអនុវត្ត គោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ហើយដែលការអនុវត្តនេះផ្តោតទៅលើ សហគមន៍ទាំងមូល ក៏ដូចជាទៅលើក្រុមជាក់លាក់នានា ព្រមទាំងបុគ្គលនៅក្នុងសហគមន៍នោះផងដែរ"[62]។ ដូច្នេះចំពោះការខូចខាត ជាលក្ខណៈសមូហភាព អង្គបុរេជំនុំជម្រះមិនតម្រូវឲ្យមានភាពជិតគ្នា ផ្នែករូបរាងកាយរវាងសមាជិក នៃក្រុមមនុស្ស ឬសហគមន៍គោលដៅតែមួយឡើយ។

31. ការអនុវត្តគោលការណ៍ស្តីពី "ការខូចខាតជាសមូហភាព" របស់ អ.វ.ត.ក ស្របគ្នាជាមួយការអនុវត្តជាអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ថា "ប្រហែលជាច្បាស់ហើយថា ព្យសនកម្មអាចមានលក្ខណៈជាបុគ្គល និងជាសមូហភាព"[63]។ គោលការណ៍យុត្តិធម៌ជាមូលដ្ឋានឆ្នាំ១៩៨៥ របស់អង្គការសហប្រជាជាតិ សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានលើអំណាច បានកំណត់និយមន័យ "ជនរងគ្រោះ"

[60] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៩៣ (ដោយគូសបញ្ជាក់បន្ថែម)។

[61] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៨៨ (ដោយគូសបញ្ជាក់បន្ថែម)។

[62] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

[63] រដ្ឋអាជ្ញា តទល់នឹង *Thomas Lubanga Dyilo*, ICC-01/04-01/06-1432 សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញានិងមេធាវីការពារក្តី ប្រឆាំងដីកាសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង I ស្តីពីការចូលរួមរបស់ជនរងគ្រោះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

ថាជា "បុគ្គលទាំងឡាយ ទោះជាឯកត្តបុគ្គល ឬជាសមូហភាពក្តី ដែលបានទទួលរងអន្តរាយ"[64]។ បើយោងតាមគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន ឆ្នាំ២០០៥ "ទម្រង់នៃការធ្វើឱ្យក្លាយជាជនរងគ្រោះនាពេលនោះ ជាពិសេសនៅពេលធ្វើឡើងប្រឆាំងនឹងមនុស្ស ក៏អាចត្រូវបានប្រព្រឹត្តឡើង*ប្រឆាំងនឹងក្រុមមនុស្សដែលត្រូវបានកំណត់គោលដៅ ជាសមូហភាពផងដែរ*"[65]។ ស្ថាប័នសិទ្ធិមនុស្សជាច្រើនក៏បានទទួលស្គាល់ផងដែរថា សមូហភាពមានសិទ្ធិ និងមានលទ្ធភាពទទួលរងព្យសនកម្ម ដែលតម្រូវឱ្យមានសំណងសម្រាប់ពួកគេ[66]។

32. បើយោងតាមដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម យឹម ទិត្យ ត្រូវទទួលខុសត្រូវចំពោះការវាយប្រហារ ដែលមានគោលដៅទៅលើក្រុម ឬសហគមន៍ជាក់លាក់ នៅក្នុងភូមិភាគ

---

[64] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្មនិងការរំលោភបំពានអំណាច U.N.G.A Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១។

[65] គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពី សិទ្ធិក្នុងការទទួលបានឧបាស្រ័យ និងសំណង សម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ U.N.G.A. Res. 60/147 ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ (បុព្វកថា) (ដោយគូសបញ្ជាក់បន្ថែម)។

[66] សូមមើល ជាឧទាហរណ៍ គណៈកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក, *មជ្ឈមណ្ឌលអភិវឌ្ឍន៍សិទ្ធិជនជាតិភាគតិច (ប្រទេសកេនយ៉ា) និងក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ ក្នុងនាមក្រុមប្រឹក្សាសុខុមាលភាពអង់ដូរ៉ស់ តទល់នឹង ប្រទេសកេនយ៉ា* ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ២៤៨ (គូសបញ្ជាក់ថា រដ្ឋមាន "កាតព្វកិច្ចកម្រិតខ្ពស់ ក្នុងការចាត់វិធានការវិជ្ជមាន ដើម្បីការពារក្រុម និងសហគមន៍នានា ដូចជាសហគមន៍អង់ដូរ៉ស់នេះ")។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ *មតិយោបល់ទូទៅលេខ ២១, សិទ្ធិរបស់បុគ្គលគ្រប់គ្នាក្នុងការចូលរួមក្នុងជីវភាពវប្បធម៌* E/C.12/GC/21 ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៣៧ (ជនជាតិដើមភាគតិចមានសិទ្ធិធ្វើសកម្មភាពជាសមូហភាព ដើម្បីធានានូវការគោរពសិទ្ធិរបស់ខ្លួន ក្នុងការថែរក្សា គ្រប់គ្រង ការពារ និងអភិវឌ្ឍន៍មរតកវប្បធម៌ ចំណេះវិជ្ជាប្រពៃណី ការបង្ហាញទំនៀមទម្លាប់វប្បធម៌របស់ខ្លួន [...] រដ្ឋជាភាគីត្រូវតែគោរពគោលការណ៍យល់ព្រមដោយសេរីជាមុន និងផ្អែកលើព័ត៌មានគ្រប់គ្រាន់ របស់ជនជាតិដើមភាគតិច ក្នុងគ្រប់កិច្ចការទាំងអស់ ដែលត្រូវបានគ្របដណ្តប់ ដោយសិទ្ធិជាក់លាក់ទាំងនេះ")។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក រឿងក្តី ជនជាតិដើមភាគតិច *Kichwa* នៃអំបូរ *Sarayaku* *តទល់នឹង ប្រទេសអេក្វាឌ័រ* សាលក្រម (អង្គសេចក្តី និងសំណង) ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ២៣១ ដល់២៣២, ២៨៤ (បញ្ជាក់អះអាងថា "ច្បាប់អន្តរជាតិស្តីពីសហគមន៍ និងជនជាតិដើមភាគតិច ឬកុលសម្ព័ន្ធ ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមទាំងនេះជាកម្មវត្ថុសមូហភាពនៃច្បាប់អន្តរជាតិ មិនត្រឹមតែទទួលស្គាល់ជាសមាជិកសហគមន៍ទាំងនោះឡើយ [...]"។ ក្រោយមកទៀត រកឃើញថា ប្រទេសអេក្វាឌ័រ បានរំលោភបំពានទៅលើ "សិទ្ធិទទួលបានទ្រព្យសម្បត្តិសមូហភាពរបស់ជនជាតិ Sarayaku" និងសម្រេចឱ្យប្រទេសអេក្វាឌ័រ ទទួលខុសត្រូវចំពោះជនជាតិទាំងនេះ ជាភាគីដែលទទួលរងការខូចខាត)។

ពាយ័ព្យ រួមទាំងការវាយប្រហារទៅលើ ប្រជាជនវៀតណាម[67] "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី"[68] ប្រជាជនមកពីភូមិភាគបូព៌ា[69] អតីតអ្នកជាប់ពាក់ព័ន្ធរបបសាធារណរដ្ឋខ្មែរ និង លន់ នល់[70] កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលគេគិតថាក្បត់ (រួមទាំងកម្មាភិបាលមកពី ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ)[71] ជនជាតិចិន[72] អតីតព្រះសង្ឃពុទ្ធសាសនា[73] ខ្មែរក្រោម[74] អ្នកដែលសង្ស័យថាជា "គិញ" របស់ សេអ៊ីអា និងកាហ្សេបេ[75] និងវណ្ណៈដែលមិនគួរជាទីពេញចិត្ត[76]។ យោងទៅលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ការសន្មតអំពីការខូចខាតជាសមូហភាព ដែលកើតចេញពីព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់បានទទួលរង នៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី បានពង្រីកវិសាលភាពដល់សមាជិកទាំងអស់ នៃក្រុមឬសហគមន៍ដែលជាគោលដៅជាក់លាក់ ដោយមិនគិតអំពីទីកន្លែងរបស់ពួកគេឡើយ។

33. នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់គោលការណ៍ការខូចខាតជាសមូហភាព របស់អង្គបុរេជំនុំជម្រះ ដោយសារតែគោលការណ៍នេះទាក់ទងជាមួយ ភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបានបញ្ជាក់ថា "ជនរង

[67] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨, ៣១១។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី កថាខណ្ឌ ១៧, ៥៩។

[68] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨, ៣១១, ១០២២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី កថាខណ្ឌ ១៧, ៥៩។

[69] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១២, ៣១៣, ១០២២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៥៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ ១១-២០។

[70] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១០, ១០២២។

[71] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១២-៣១៦, ១០២២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី កថាខណ្ឌ ១៧, ៩៨។

[72] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨, ៣១១។

[73] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១១។

[74] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១៩៦-២៧៥។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ ១១-២០។

[75] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១១។

[76] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨ (កត់សម្គាល់ថា កម្មាភិបាលនិងប្រជាជនទូទៅត្រូវបានបញ្ជាឱ្យរក្សាការប្រុងប្រយ័ត្ន ជាប់ជាប្រចាំប្រឆាំងនឹងខ្មាំង ហើយត្រូវរាយការណ៍អំពី "ខ្មាំង" ដូចជា "សក្តិភូមិ" "នាយទុន" ដើម្បីមេដឹកនាំខ្មែរក្រហម អាចចាត់ចែងជាមួយពួកទាំងនេះ)។

គ្រោះមិនផ្ទាល់ អាចទទួលរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងជាគ្រួសារ ជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឲ្យតែពួកគាត់ជាសមាជិក នៅក្នុងក្រុមគោលដៅតែមួយ ឬក្នុងសហគមន៍តែមួយ”[77]។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ថា ជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលផ្អែកលើឋានៈណាមួយ, សហឧក្រិដ្ឋកម្មរួមក្នុងការលប់បំបាត់ខ្មែរក្រោម (សហឧក្រិដ្ឋកម្មរួម ខ) គឺមិនចាំបាច់ត្រូវកម្រិតកំណត់ដោយទីតាំងភូមិសាស្ត្រ តែចំពោះទីតាំងជាក់លាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបានទេ[78]។ ទោះជាបែបនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តគោលការណ៍ ការខូចខាតជាសមូហភាព ចំពោះក្រុមឬសហគមន៍គោលដៅដទៃទៀត ដែលបានកំណត់នៅក្នុង ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ជាជំនួសទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់លក្ខខណ្ឌតម្រូវដោយខុសឆ្គងថា សមាជិកដែលរស់នៅក្នុងក្រុម ឬសហ

---

[77] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៤។

[78] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ២៨ (ប្រកាសថាអាចទទួលស្គាល់បានចំពោះ “អ្នកដាក់ពាក្យសុំទាំងឡាយ ដែលបានទទួលរងព្យសនកម្ម ដែលជាផលវិបាកនៃ គោលនយោបាយរួមទូទាំងប្រទេស ដែលត្រូវបានចោទប្រកាន់ ... លប់បំបាត់ខ្មែរក្រោម”)។ *ប្រៀបធៀប* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៦(“ផែនការឧក្រិដ្ឋកម្មរួម មានអត្ថិភាពនៅក្នុងចំណោម មេដឹកនាំ ប.ក.ក ក្នុងការបង្កើតសង្គមមួយ មិនមានវណ្ណៈ មិនមានអាទិទេព និងមានជាតិពន្ធុតែមួយដូចគ្នា”)។ ដូច ខាងលើ កថាខណ្ឌ ៨ (“ប.ក.ក បានអនុវត្តគោលនយោបាយ មិនស្របច្បាប់របស់ខ្លួន តាមរយៈ**ខ្សែបណ្តាញមន្ទីរសន្តិសុខ នៅទូទាំងប្រទេស**”) (ដោយគូសបញ្ជាក់បន្ថែម)។ ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ [redacted] (“យឹម ទិត្យ គឺជាមនុស្សចម្បងម្នាក់ ដែលមានការទទួលខុសត្រូវ ចំពោះការអនុវត្តគោលនយោបាយ របស់ប.ក.ក ក្នុងតំបន់ដែលស្ថិតនៅក្រោម ការទទួលខុសត្រូវរបស់គាត់ ដូច្នេះគាត់បានដឹងយ៉ាងច្បាស់ថា ការអនុវត្តគោលនយោបាយទាំងបួនរបស់ ប.ក.ក អាចសម្រេចទៅបាន មានតែអនុវត្តតាមរយៈឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ទាំងនោះ”)។ សូមមើលផងដែរ ដូចខាងលើ កថាខណ្ឌ ២៨៩ (រួមទាំងខ្មែរក្រោម ក្នុងចំណោមក្រុមដែលត្រូវបានកំណត់គោលដៅ ដោយផ្អែកលើស្ថានភាព ជាច្រើនទៀត៖ “បក្សកុម្មុយនីស្តកម្ពុជា កំណត់អត្តសញ្ញាណ និងកំណត់គោលដៅ ទៅលើក្រុមប្រជាជនជាក់លាក់ ដែលចាត់ទុកថាអាចជា ការគំរាមកំហែងដល់របបកម្ពុជាប្រជាធិបតេយ្យ ឬមានទស្សនៈដែលមិនស្របជាមួយ លិទ្ធិរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចោទប្រកាន់ពី “*សកម្មភាពក្បត់*” អ្នកដែលមានទំនាក់ទំនងជាមួយអតីតរបប លន់ នល់ គិញសេអ៊ីអា កាហ្សេបេ ឬវៀតណាម (“*យួន*”) ខ្មែរក្រោម និងអ្នកដែលគេគិតថាស្ថិតក្នុងវណ្ណៈ “*មូលធន*” “*សក្តិភូមិ*” “*ម្ចាស់ដី*” ឬ “*គហបតី*””)។ សូមមើលផងដែរ ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០១៦ (ii)។

គមន៍គោលដៅតែមួយ (ប្រជាជនវៀតណាម[79] "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី"[80] ប្រជាជនមកពីភូមិភាគបូព៌ា[81] អតីតអ្នកជាប់ពាក់ព័ន្ធរបបសាធារណរដ្ឋខ្មែរ និង លន់ នល់[82] កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលគេគិតថាក្បត់ (រួមទាំងកម្មាភិបាលមកពី ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ)[83] ជនជាតិចិន[84] អតីតព្រះសង្ឃពុទ្ធសាសនា[85] អ្នកដែលសង្ស័យថាជា "គិញ" របស់ សេអ៊ីអា និងកាហ្សេបេ[86] និងវណ្ណៈដែលមិនគួរជាទីពេញចិត្ត[87]) ត្រូវតែស្ថិតនៅក្នុងភូមិភាគពាយ័ព្យ ឬទីតាំងជាក់លាក់ទាំងប្រាំមួយ នៅក្នុងភូមិភាគនិរតី ដោយប្រានចោលនូវលក្ខណៈជាសមូហភាព ដែលជាចំណុចស្នូលនៃគោលការណ៍នេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់សំអាងហេតុចំពោះការអនុវត្តខុសគ្នាស្រឡះ ពីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ស្តីពីគោលការណ៍ការខូចខាតជាសមូហភាព។

34. ក្នុងចំណោមអ្នកដែលត្រូវបានបដិសេធ មិនទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤ គឺជាជនរងគ្រោះដែលជាសមាជិក នៃក្រុមគោលដៅ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ឧទាហរណ៍ដែលបង្ហាញ

---

[79] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨, ៣១១។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ១៧, ៥៩។

[80] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨, ៣១១, ១០២២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ១៧, ៥៩។

[81] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១២-៣១៣, ១០២២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៥៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ ១១-២០។

[82] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១០, ១០២២។

[83] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១២-៣១៦, ១០២២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ១៧, ៩៨។

[84] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨, ៣១១។

[85] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១១។

[86] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១១។

[87] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០៨ (កត់សម្គាល់ថា កម្មាភិបាលនិងប្រជាជនទូទៅត្រូវបានបញ្ជាឲ្យរក្សាការប្រុងប្រយ័ត្ន ជាប់ជាប្រចាំប្រឆាំងនឹងខ្មាំង ហើយត្រូវរាយការណ៍អំពី "ខ្មាំង" ដូចជា "សក្តិភូមិ" "នាយទុន" ដើម្បីមេដឹកនាំខ្មែរក្រហម អាចចាត់ចែងជាមួយពួកទាំងនេះ)។

អំពីព្យសនកម្មដែលទទួលរង ដោយដើមបណ្តឹងរដ្ឋប្បវេណី ក្រោមគោលនយោបាយជាតិទាំងអស់នោះ ហើយដែលចាត់ទុកថាមិនអាចទទួលយកបាន គឺរួមមាន៖

(១) ជា សឿន (14-VSS-00061) បានបួសជាព្រះសង្ឃ នៅវត្តជោតានារាម នៅតំបន់មួយឈ្មោះបឹងកុក។ នៅក្នុងឆ្នាំ១៩៧៣ ខ្មែរក្រហមបានជម្លៀសអ្នកដាក់ពាក្យសុំ និងព្រះសង្ឃ ២៥អង្គផ្សេងទៀត ទៅស្នាក់នៅមួយយប់ នៅវត្តលពៀក (ល្ពាក់) ក្នុងឃុំស្រេក ស្រុកកំពង់សៀម។ កម្មាភិបាលខ្មែរក្រហមបានបង្គាប់ និងបញ្ចូលមនោគមន៍ដល់ព្រះសង្ឃ ដោយទូលព្រះសង្ឃថា ព្រះសង្ឃប្រៀបបាននឹងព្រូនរបស់សង្គម ហើយត្រូវតែសឹក និងធ្វើការងារដូចប្រជាជនទូទៅ។ អ្នកដាក់ពាក្យសុំបានចាប់ផ្តើម និមន្តពីវត្តមួយទៅវត្តមួយទៀត ដើម្បីគេចចេញពីការចាប់ផ្សឹក។ នៅពេលមួយនោះ កម្មាភិបាលខ្មែរក្រហមបានបង្គាប់គាត់ ឱ្យសិក្សា "ឯកសារបដិវត្ត" របស់របបខ្មែរក្រហម ចូលរួមការប្រជុំជីវភាព និងឱ្យសឹក។ អ្នកដាក់ពាក្យសុំរត់គេចទៅវិហារធំ និងរកាគយ ហើយនៅទីនោះខ្មែរក្រហមបង្គាប់ឱ្យអ្នកដាក់ពាក្យសុំជួយកសាងទំនប់តាម៉ាន ជីកប្រឡាយនៅភូមិថ្មី និងសែងដី ដោយគាត់ធ្វើការងារទាំងអស់នេះទាំងដែលនៅជាព្រះសង្ឃ។ នៅពេលដែលអ្នកដាក់ពាក្យសុំ ត្រឡប់មកវិហារធំវិញនៅក្នុងឆ្នាំ ១៩៧៥ មេដឹកនាំខ្មែរក្រហមទាមទារចុងក្រោយថា គាត់ត្រូវតែសឹក ហើយចាត់តាំងគាត់ទៅកងចល័ត។ នៅពេលនោះព្រះសង្ឃទាំងអស់ ដែលគង់នៅវត្តវិហារធំ ត្រូវបានគេផ្សឹកអស់ហើយ ហើយវត្តត្រូវបានខ្មែរក្រហម ប្រើប្រាស់ដើម្បីស្តុកអាចម៍គោ ព្រះពុទ្ធរូបត្រូវបានវាយកម្ទេច ហើយសាលារៀនក្នុងវត្ត ត្រូវបានគេយកធ្វើជាឃ្លាំង និងបន្ទាយសម្រាប់កម្មាភិបាលខ្មែរក្រហម។ នៅចុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំត្រូវបានគេចាប់ចង ហើយបញ្ជូនទៅរៀនសូត្រស្រុកព្រៃឈរ ដោយចោទប្រកាន់ថាគាត់គាំទ្រព្រះពុទ្ធសាសនា ហើយកាន់ជើងព្រះសង្ឃ ប្រឆាំងនឹងរបប។ អ្នកដាក់ពាក្យសុំត្រូវបានគេដោះលែងវិញ នៅមួយថ្ងៃក្រោយមក ហើយត្រូវគេព្រមានមិនឱ្យនិយាយ អំពីពុទ្ធសាសនា ឬទស្សនវិទ្យាព្រះសង្ឃទៀតទេ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៧៦ អ្នកដាក់ពាក្យសុំត្រូវបានគេចាប់ចង វាយនឹងច្រវ៉ាក់កង ដោយសារតែលួចចេញទៅរកអាហារ។ នៅក្នុងឆ្នាំ១៩៧៧ អ្នកដាក់ពាក្យសុំ ត្រូវបានបង្ខំឱ្យរៀបការ

ជាមួយ ឬ សម្បត្តិ និងគូស្រករដទៃទៀតចំនួន៦៥គូ ក្រោមការឃ្លាំមើលយ៉ាងប្រុងប្រយ័ត្ន របស់មេដឹកនាំខ្មែរក្រហមនៅទីនោះ[88]។

(២) នុត សារុន (11-VSS-00152) និងភរិយាព្រមទាំងកូនបីនាក់របស់គាត់ រស់នៅភូមិខ្នុរខាងត្បូង ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ចាប់ពីខែមេសា រហូតដល់ខែកក្កដា ឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំត្រូវបានចាត់តាំង ឲ្យទៅសង់ទំនប់សន្ទូទឹក ដែលមានកម្ពស់មួយម៉ែត្រ ហើយលាតសន្ធឹងចម្ងាយពីរគីឡូម៉ែត្រ។ គាត់ក៏ត្រូវសង់ប្រឡាយនានា នៅតាមវាលស្រែ ហើយត្រូវធ្វើស្រូវនៅជិតភូមិរបស់គាត់។ នៅចុងខែកក្កដា ឆ្នាំ១៩៧៥ មេភូមិឈ្មោះ សូ ឈុន បានបញ្ជាឲ្យកងឈ្លប បួនទៅប្រាំមួយនាក់ មកចាប់ខ្លួនអ្នកដាក់ពាក្យសុំ ដោយចោទប្រកាន់ថាជា ភ្នាក់ងារសេអ៊ីអា ឬកាហ្សេបេ ឬវៀតណាម។ អ្នកដាក់ពាក្យសុំត្រូវបានឃុំឃាំង នៅស្រុកមានជ័យថ្មី ខេត្តស្វាយរៀង។ នៅពេលនោះ អ្នកដាក់ពាក្យសុំត្រូវបានបញ្ជូនទៅឃុំឃាំង នៅមន្ទីរសន្តិសុខវត្តចាស់ រួមជាមួយអ្នកជាប់ឃុំដទៃទៀតប្រាំបីនាក់ ដែលម្នាក់ក្នុងចំណោមនោះ ជាបងប្រុសរបស់គាត់ឈ្មោះ នុត ស៊ីម។ បីថ្ងៃដំបូង អ្នកដាក់ពាក្យស្រេកឃ្លាន ដោយសារគេមិនផ្តល់អាហារអ្វីឡើយ។ បន្ទាប់មកពួកឈ្លបបានសួរចម្លើយគាត់ និងវាយគាត់រហូតដល់សន្លប់។ ចាប់ពីខែមករា រហូតដល់ខែមិថុនា ឆ្នាំ១៩៧៦ អ្នកដាក់ពាក្យសុំ និងអ្នកជាប់ឃុំដទៃទៀត ចំនួន២៧នាក់ ត្រូវបានគេបង្ខំឲ្យធ្វើការជាទម្ងន់ ដូចជាជីកប្រឡាយយ៉ាងវែង ចាប់ពីភូមិកៀនតាសៀវ ឃុំស្វាយយា ទៅដល់បឹងរៃ នៅក្នុងឃុំក្រោលគោ (ឃុំទាំងពីរនៅក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)។ ប្រឡាយនេះមានមុខកាត់ប្រាំម៉ែត្រ និងជម្រៅបីម៉ែត្រ។ អ្នកដាក់ពាក្យសុំនិងអ្នកទោសដទៃទៀត ត្រូវបានបង្ខំឲ្យធ្វើការ ចាប់ពីម៉ោង៦ព្រឹក រហូតដល់ម៉ោង៥ល្ងាច ជារៀងរាល់ថ្ងៃ ហើយពេលចប់ការងារ ត្រូវបានបញ្ជូនត្រឡប់ទៅមន្ទីរសន្តិសុខវត្តចាស់។ នៅទីនោះពួកគាត់ត្រូវបានគេដាក់ខ្នោះមួយយប់ទល់ភ្លឺ ហើយទទួលបានរបបអាហារ ត្រឹមបបររាវមួយវែកក្នុងមួយថ្ងៃ។ ជាចុងក្រោយ នៅចុងខែមិថុនា ឆ្នាំ១៩៧៦ អ្នកដាក់ពាក្យសុំនិងអ្នកទោសប្រាំនាក់ផ្សេងទៀត ត្រូវបានគេដោះលែង ហើយឲ្យទៅធ្វើការងារ នៅតាមការដ្ឋាននានានៅទូទាំងស្រុក។ បងប្រុសរបស់អ្នកដាក់ពាក្យសុំឈ្មោះ នុត

[88] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/1486** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សឿន ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ នៅត្រង់ 001145578-80។

ស៊ីម មិនត្រូវបានដោះលែងឡើយ ហើយគាត់បានស្លាប់ដោយសារទារុណកម្ម នៅក្នុងមន្ទីរសន្តិសុខវត្តចាស់ នៅក្នុងឆ្នាំ១៩៧៦[89]។

(៣) នៅពេលខ្មែរក្រហម កាន់កាប់ប្រទេស តែ គឹមស៊ាង (11-VSS-00015) និងប្ដីរបស់គាត់ រួមជាមួយកូនប្រុសពីរនាក់ រស់នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅក្នុងឆ្នាំ១៩៧៦ គាត់ត្រូវបានគេជម្លៀសទៅស្រុកផ្សេង ទៅធ្វើពលកម្មដោយបង្ខំ ប៉ុន្តែក្រោយមកគាត់ត្រូវបានបញ្ជូនត្រឡប់មកស្រុកកំណើតវិញ នៅពេលគាត់មានផ្ទៃពោះ។ ក្នុងអំឡុងពេលនោះ គាត់ត្រូវបានបង្ខំឲ្យធ្វើការងារធ្ងន់ លើដីនៅការដ្ឋានបឹងធំ ហើយទទួលបានត្រឹមតែ បបរាវពីរចានក្នុងមួយថ្ងៃ។ នៅពេលដែលគាត់មានផ្ទៃពោះបួនខែ អ្នកដាក់ពាក្យសុំបានរលូតកូន។ ក្រោយមកបន្ទាប់ពីសម្រាកព្យាបាលបានបន្តិច គាត់ត្រូវបានគេឲ្យរែកដីលេខមួយ ឲ្យសហករណ៍។ អ្នកដាក់ពាក្យសុំអាចរស់រានមានជីវិត (រហូតដល់ឆ្នាំ១៩៧៩) ប៉ុន្តែបងស្រីទាំងពីរនាក់របស់គាត់ឈ្មោះ ចែហ្មួយ និងចែគី និងប្ដីព្រមទាំងកូនបានស្លាប់។ នៅក្នុងឆ្នាំ១៩៧៧ ពួកកម្មាភិបាលភូមិភាគនិរតី បានចោទប្រកាន់បងស្រីទាំងពីរ របស់អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់ពួកគាត់ថា ជាគិញសេអ៊ីអា ជាជនជាតិចិន។ ដំបូងបងស្រីឈ្មោះ គី និងគ្រួសាររបស់គាត់ដែលមានសមាជិក៦នាក់ ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅភូមិទីប្រាំមួយ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ហើយពួកគាត់ត្រូវបានគេសម្លាប់នៅទីនោះ នៅក្បែរទន្លេជិតវត្តត្នោត។ ក្រោយមកបងស្រីឈ្មោះ ហ្មួយ បងថ្លៃ និងកូន១បួននាក់ ត្រូវបានចាប់ខ្លួនដាក់ឡាន ហើយយកទៅសម្លាប់នៅជិតភ្នំសន្ទុក ក្នុងខេត្តកំពង់ធំ។ ប្អូនប្រុសរបស់អ្នកដាក់ពាក្យសុំក៏ត្រូវបានគេសម្លាប់នៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ចំណែកក្មួយប្រុសរបស់គាត់ត្រូវបានគេបង្ខំឲ្យរៀបការ ជាមួយគូស្រករដទៃទៀតចំនួន៧១គូ នៅភូមិគោកក្រៀម ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម[90]។

(៤) នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសដោយបង្ខំ សៀង ចាន់ថឺ (13-VSS-00396) និងក្រុមគ្រួសាររបស់គាត់ រួមជាមួយប្រជាជនដទៃទៀត មកពីភូមិនៅក្បែរទីរួមខេត្ត

---

[89] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/310** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នុត សារុន ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ នៅត្រង់ 00558827-29។

[90] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/225** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ តែ គឹមស៊ាង ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ នៅត្រង់ 00552356-57។

ស្វាយរៀង ទៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ នៅភូមិឈូកស ប្រជាជនមូលដ្ឋានមិនស្វាគមន៍ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសារគាត់ឡើយ ដោយសារតែពួកគេត្រូវគេចាត់ទុកថាជា "ប្រជាជនថ្មី" និង "សក្តិភូមិ"។ អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់គាត់មានសម្បុរស ដែលធ្វើឲ្យអ្នកមូលដ្ឋានចោទប្រកាន់ពួកគាត់ថាជា "អាយ៉ងយួន"។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសាររបស់គាត់ ត្រូវបានគេបញ្ជូនទៅធ្វើការ នៅភូមិឬស្សីព្រៃ ក្នុងស្រុកស្វាយជ្រំ។ នៅទីនោះមេដឹកនាំខ្មែរក្រហម ឲ្យអ្នកដាក់ពាក្យសុំនិងក្រុមគ្រួសារ ធ្វើការងារជាទម្ងន់ ហាមឃាត់ពួកគាត់មិនឲ្យសម្រាកគ្រប់គ្រាន់ ហើយផ្តល់របបអាហារដល់ពួកគាត់ ដែលជាប្រជាជនថ្មី ត្រឹមតែពាក់កណ្តាលនៃរបបអាហារ ដែលផ្តល់ដល់ប្រជាជនមូលដ្ឋាន។ ពួកគាត់ត្រូវបានគេបង្ខំឲ្យសង់ភ្លឺ នៅតាមវាលស្រែ ជីកប្រឡាយនិងជីកដី។ អ្នកដាក់ពាក្យសុំទទួលរងទារុណកម្ម ដោយសារការភ័យខ្លាចត្រូវគេចាប់រំលោភ មុនពេលសម្លាប់ចោល ដូចដែលកូនស្រីក្មេងរបស់ គ្រួសារវៀតណាមតែមួយ នៅក្នុងភូមិបានទទួលរងនោះ។ អ្នកដទៃទៀតនៅក្នុងសហករណ៍ មិនរាប់រកគ្រួសារគាត់ ដោយសារតែខ្លាចត្រូវគេចោទថាមានកំហុស ព្រោះទាក់ទងជាមួយជនជាតិវៀតណាម។ ក្រុមគ្រួសារអ្នកដាក់ពាក្យសុំ ព្យាយាមធ្វើការខ្លាំងក្លា ហើយមិនដែលតវ៉ាអំពី ទុក្ខលំបាកនិងការឈឺចាប់របស់ខ្លួនឡើយ ព្រោះពួកគេគឺជាក្រុមគ្រួសារកាត់វៀតណាម។ ពួកគាត់ភ័យខ្លាចត្រូវគេយកទៅសម្លាប់ នៅពេលណាមួយ ជាពិសេសបើពួកគាត់បង្កបញ្ហា។ ទោះជាយ៉ាងនេះក្តី នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ បងប្រុសរបស់អ្នកដាក់ពាក្យសុំឈ្មោះ ជ្រូក ចន្លន ត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខមួយ ស្ថិតនៅក្នុងវត្តតាជ័យ ឃុំកំពង់ចម្លង ស្រុកស្វាយជ្រំ ហើយក្រោយមកត្រូវឃុំនៅវត្តឈើទាល និងវត្តស្លា ប្រហែលប្រាំទៅប្រាំមួយខែ។ ជ្រូក ចន្លន ត្រូវបានគេដោះលែងរយៈពេលខ្លី ហើយបានរៀបរាប់ពីទុក្ខសោកទាំងទឹកភ្នែក ប្រាប់ក្រុមគ្រួសារថា គាត់ត្រូវគេបង្ខំឲ្យធ្វើការជាទម្ងន់ ត្រូវគេវាយដូចសត្វធាតុ ត្រូវគេសួរចម្លើយ និងបង្អត់អាហារពេលជាប់ឃុំឃាំង។ នៅថ្ងៃទីបីដែលគាត់មកនៅផ្ទះ កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យចន្លន ទៅជាមួយវា ទៅលីតវ៉ាន់ឲ្យឈ្លប ប៉ុន្តែមួយសប្តាហ៍ក្រោយមក ក្រុមគ្រួសារបានទទួលព័ត៌មានថា ចន្លនត្រូវបានគេសម្លាប់។ នៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៦ បងប្រុសម្នាក់ទៀតរបស់អ្នកដាក់ពាក្យសុំឈ្មោះ ជ្រូក ចន្ថា ត្រូវបានចាប់ខ្លួនហើយឃុំឃាំងនៅវត្តតាសួស ក្នុងឃុំតាសួស ស្រុកស្វាយជ្រំ ហើយក្រោយមកត្រូវបានជម្លៀសចេញ និងបន្ទាប់ពីការចូលលុកលុយរបស់វៀតណាម នៅក្នុងតំបន់នេះ នៅចុងឆ្នាំ១៩៧៧ គាត់ត្រូវបានគេសម្លាប់នៅតាជ័យ ដោយសារ

តែគាត់ជាជនក្បត់អង្គការ។ នៅក្នុងឆ្នាំ១៩៧៨ ឪពុករបស់អ្នកដាក់ពាក្យសុំឈ្មោះ ជ្រុក ធឿង ត្រូវបានគេចោទថាជា "ខ្មាំងយួន" ហើយត្រូវគេគម្រាមសម្លាប់។ ដោយសារតែគាត់មិនអាចទ្រាំនឹងការគិត អំពីការសម្លាប់ដោយពួកខ្មែរក្រហម ទើបគាត់សម្រេចចិត្តធ្វើអត្តឃាតដោយចងក។ ម្ដាយរបស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម ញឹម ត្រូវបានចាប់ខ្លួន នៅចុងឆ្នាំ១៩៧៨ ហើយត្រូវគេចោទថាក្បត់អង្គការ។ ក្រោយពេលដែលប្ដីនិងកូនរបស់គាត់ស្លាប់ទៅ ម្ដាយរបស់អ្នកដាក់ពាក្យសុំ លែងចេញពីផ្ទះអស់រាប់ខែ ហើយគាត់ព្យាយាមធ្វើអត្តឃាត។ អ្នកដាក់ពាក្យសុំភ័យខ្លាចថា គាត់និងបងប្អូនក្លាយជាក្មេងកំព្រា ទើបអង្វរម្ដាយឲ្យនៅរស់។ សូម្បីនៅក្រោយពេលរបបនេះដួលរលំទៅក្ដី អ្នកដាក់ពាក្យសុំតែងឃើញម្ដាយរបស់គាត់ សម្លឹងមើលទៅឆ្ងាយ វង្វេងវង្វាន់ ឬឃុំស្ងាត់ម្នាក់ឯងនៅក្នុងបន្ទប់[91]។

(៥) នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នៅក្នុងឆ្នាំ១៩៧៥ ស៊ាង រី (12-VSS-00669) ត្រូវបានជម្លៀសទៅភូមិអណ្ដូងពោធិ៍ ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដែលនៅទីនោះ គាត់ត្រូវបានគេចាត់ឲ្យធ្វើស្រែ ជួយសង់ទំនប់ស្រូចចេក និងសង់ប្រឡាយចាប់ពីព្រលឹមទល់ព្រលប់ ដោយគ្មានអាហារគ្រប់គ្រាន់។ អ្នកដាក់ពាក្យសុំត្រូវបានគេចោទជាញឹកញាប់ ថាមិនអាចបំពេញតាមការងារដែលបានបែងចែក។ នាពេលក្រោយមកនៅក្នុងរបបនេះ បងប្រុសរបស់អ្នកដាក់ពាក្យសុំ បានក្លាយជាជនរងគ្រោះ នៃការបោសសម្អាតផ្ទៃក្នុង របស់បក្សកុម្មុយនីស្តកម្ពុជា។ ទីមួយគឺនៅក្នុងឆ្នាំ១៩៧៧ បងប្រុសរបស់អ្នកដាក់ពាក្យសុំឈ្មោះ សៀង សឿន ប្រធានកងស្ករ ត្រូវបានគេចោទថាជាខ្មែរស ហើយត្រូវគេចាប់ខ្លួននៅម៉ោង៦ល្ងាច នៅក្នុងភូមិអណ្ដូងពោធិ៍ ឃុំក្រឡា ហើយបាត់ខ្លួនរហូតមក។ បន្ទាប់មកបងប្រុសម្នាក់ទៀតឈ្មោះ សៀង រឿន ដែលជាកងឈ្លបខ្មែរក្រហម ត្រូវបានគេចោទថាជាខ្មែរស ឬជាផ្នែកនៃបណ្ដាញភូមិភាគបូព៌ារបស់តាធុច ហើយត្រូវមេភូមិចម្រើនផល ឃុំតាអ៊ុង ស្រុកកំពង់សៀម ចាប់ខ្លួនយកទៅបាត់ដានរហូត[92]។

---

[91] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/1234** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៀង ចាន់ធី ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦នៅត្រង់ 01192659-62។ សំណុំរឿង ០០៤ ឯកសារ **D5/1234/4/4.1** ប្រតិចារឹកសវនាការលើអង្គសេចក្ដី សំណុំរឿង០០២/០២ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦នៅត្រង់ 01454524, 01454529-30, 01454535។ សំណុំរឿង ០០៤ ឯកសារ **D219/792.1.4** ប្រតិចារឹកសវនាការលើអង្គសេចក្ដី សំណុំរឿង០០២/០២ ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦នៅត្រង់ 01452771-79។

[92] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/673** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ាង រី ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ នៅត្រង់ 00911551-52។

(៦) នៅមុនឆ្នាំ ១៩៧៥ ពិន ដន (11-VSS-00027) គឺជាព្រះសង្ឃនៅភ្នំពេញ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ត្រូវបានគេបញ្ជា ឲ្យចាកចេញពីវត្ត និងចេញពីទីក្រុង តាមផ្លូវជាតិលេខ៦ ហើយបានទៅដល់ភូមិទួលត្រាច ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅទីនោះអ្នកដាក់ពាក្យសុំ ត្រូវបានកំណត់ថាជា "ប្រជាជនថ្មី" ហើយត្រូវផ្សឹកនៅវត្តភូមិវិហារ ហើយដំបូងជាមួយឪពុកម្តាយរបស់គាត់ ត្រូវបានបញ្ជូនទៅភូមិគងមហារ ហើយបន្ទាប់មកទៅភូមិស្អាង ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ នៅទីនោះគាត់ត្រូវបានគេបង្ខំ ឲ្យរែកដី និងធ្វើភ្លឺប្រឡាយធំៗ នៅតាមវាលស្រែ។ អ្នកដាក់ពាក្យសុំជួបការលំបាកយ៉ាងខ្លាំង ជាពិសេសដោយសារតែគេបែងចែករបបអាហារ ទើបអង្ករត្រឹមតែបីកំប៉ុង សម្រាប់មនុស្ស២០ទៅ៣០នាក់។ នៅក្នុងឆ្នាំ១៩៧៧ អ្នកដាក់ពាក្យសុំត្រូវបានបង្ខំ ឲ្យរៀបការជាមួយនារីម្នាក់ឈ្មោះ វ៉ា លីនហ៊ន រួមជាមួយគូស្រកដទៃទៀតចំនួនបួនគូរ។ អ្នកដាក់ពាក្យសុំជួបប្រទះតែការសម្លាប់ ដោយមានម្តងនោះមានមនុស្សជាង១៥០នាក់ នៅក្នុងកងចល័តមួយ ត្រូវបានគេចង់បណ្តើរយកទៅសម្លាប់ នៅឯគោកព្រីង។ អ្នកដាក់ពាក្យសុំបាត់បង់សមាជិកគ្រួសារជាច្រើន ដោយសារត្រូវចោទប្រកាន់ថា មិនស្មោះត្រង់ជាមួយអង្គការ ឬជាខ្មាំងដោយសារតែពួកគេ មានទំនាក់ទំនងជាមួយរបបលន់ នល់។ ឪពុកអ្នកដាក់ពាក្យសុំ ដែលតវ៉ាពីភាពស្រេកឃ្លាន និងស្ថានភាពធ្វើការដ៏អាក្រក់ ត្រូវបានគេចាប់ចងមុខបណ្តើរយកទៅសម្លាប់ នៅព្រៃទួលព្រិច ស្ថិតនៅក្នុងភូមិគង់មហា។ បងប្រុសរបស់អ្នកដាក់ពាក្យសុំឈ្មោះ ម៉ៅ ចន ដែលជាគិលានុបដ្ឋាក ត្រូវបានគេចោទប្រកាន់ថាជា អតីតទាហានលន់ នល់ ហើយត្រូវគេសម្លាប់នៅព្រៃទួលព្រិច។ ប្អូនជីដូនមួយគាត់ឈ្មោះ ឈួន សន ដែលធ្លាប់ធ្វើជាទាហានលន់ នល់ ត្រូវបានគេយកទៅសម្លាប់នៅភូមិក្រសាំងពុល ឃុំមាន ស្រុកព្រៃឈរ ខេត្តកំពង់ចាម[93]។

(៧) នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៨ ភរិយា និងកូនទាំងពីរនាក់របស់ ជា ជឿង ត្រូវបានឈ្មោះ សាត ជាមេសហករណ៍ កោះហៅទៅមន្ទីរឃុំ នៅក្នុងភូមិក្បាលជួរ ឃុំសំបុក ស្រុកក្រចេះ ខេត្តក្រចេះ។ បន្ទាប់មកពួកគាត់ត្រូវបាន "បញ្ជូនឲ្យទៅជួបអង្គការ"។ ភរិយារបស់អ្នកដាក់ពាក្យសុំ ត្រូវបានគេចាប់រំលោភហើយសម្លាប់ ចំណែកកូនៗរបស់គាត់ ត្រូវកម្មាភិបា

[93] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/230** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពិន ដន ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០នៅត្រង់ 00864764។ សំណុំរឿង ០០៤ ឯកសារ **D219/17** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេនី ពិន ដន ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ នៅត្រង់ 01047083-84។

លខ្មែរក្រហមសម្លាប់ ដោយសារតែគេជឿថាពួកគាត់ជាជនជាតិវៀតណាម។ អ្នកដាក់ពាក្យសុំបានដឹងថា ពួកឈ្លបរះពោះប្រពន្ធនិងកូនរបស់គាត់ ហើយញាត់ស្មៅចូល[94]។

(៨) នៅខែមេសា ឆ្នាំ១៩៧៥ ផាត់ ហាន (12-VSS-00805) និងឪពុកម្តាយ បងប្អូនបង្កើត១០នាក់ និងជីដូនជីតារបស់គាត់ ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ ហើយធ្វើដំណើរទៅស្រុកកំណើតខាងម្តាយគាត់ នៅឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ។ នៅទីនោះអ្នកដាក់ពាក្យសុំនិងក្រុមគ្រួសាររបស់គាត់ ត្រូវបានបែងចែកទៅតាមក្រុមធ្វើការ។ ម្តាយនិងយាយរបស់គាត់ត្រូវបានគេចាត់ឲ្យទៅធ្វើការ នៅក្នុងកងមនុស្សចាស់ មើលថែកុមារ ចំណែកឪពុកគាត់ត្រូវបានគេចាត់ ឲ្យទៅធ្វើការងារនៅកងភ្ជួរ។ ជីតារបស់អ្នកដាក់ពាក្យសុំ បានស្លាប់ដោយសារជំងឺ ហើយមិនមានថ្នាំសង្កូវឬការព្យាបាល។ អ្នកដាក់ពាក្យសុំនិងកុមារដទៃទៀត ត្រូវបានគេចាត់ឲ្យទៅធ្វើការ នៅក្នុងកងកុមារ នៅការដ្ឋានទំនប់នៅវត្តបារាយ ក្នុងភូមិបារាយ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ។ ដោយសារតែការអត់អាហារនិងពលកម្មដោយបង្ខំ អ្នកដាក់ពាក្យសុំធ្លាប់ខ្លួនស្គមរីងរៃ។ គាត់នឹកក្រុមគ្រួសាររបស់គាត់ ហើយលួចរត់ជាញឹកញាប់ ពីការដ្ឋានរបស់គាត់ ដើម្បីទៅជួបក្រុមគ្រួសារ។ គាត់ត្រូវបានគេបញ្ជូនទៅអប់រំ ឬទទួលរងការងារកាន់តែធ្ងន់ធ្ងរជាងមុន នៅពេលដែលគាត់ត្រឡប់មក កងធ្វើការងាររបស់គាត់វិញ។ មានម្តងនោះនៅពេលគាត់ត្រឡប់មកផ្ទះ គាត់បានឃើញប្អូនស្រីគាត់ជិតស្លាប់ ដោយសារតែរាគរូសស្រួចស្រាវ។ នៅក្នុងរដូវវស្សាឆ្នាំ១៩៧៦ អ្នកដាក់ពាក្យសុំបានដឹងថា ឪពុករបស់គាត់បានស្លាប់ ប៉ុន្តែគាត់មិនហ៊ានសុំអនុញ្ញាតមកមើលឪពុកឡើយ ដោយសារតែគាត់ខ្លាចត្រូវគេយកទៅសម្លាប់។ គាត់បានត្រឹមតែពួនយំប៉ុណ្ណោះ។ ពួកកងឈ្លបខ្មែរក្រហម ចាប់បានពេកគាត់យំ ហើយគាត់ត្រូវគេយកទៅអប់រំម្តងទៀត។ ពេលនេះគាត់ត្រូវបានគេបង្អត់អាហារ ហើយចងជាប់នឹងសសរ និងវាយនឹងដំបង។ បន្ទាប់មកគាត់ត្រូវបានគេសួរចម្លើយ ក្នុងនាមជា "ប្រជាជន១៧មេសា" អំពីប្រវត្តិរូបឪពុកនិងជីដូនគាត់ ប៉ុន្តែអ្នកដាក់ពាក្យសុំមិនបាននិយាយអ្វីឡើយ។ នៅក្នុងឆ្នាំ១៩៧៦ដដែលនេះ ប្អូនស្រីរបស់គាត់ឈ្មោះ មុំ ធ្លាក់ខ្លួនឈឺហើយស្លាប់ ដោយសារតែគ្មានការព្យាបាល។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ម្តាយរបស់គាត់ត្រូវបានខ្មែរក្រហមចាប់ខ្លួន ដោយសារតែលួចអំបិល ប៉ុន្តែគាត់ត្រូវបានដោះលែងវិញ ដោយសារតែ

---

[94] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/483** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ជឿង ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ នៅត្រង់ 00528048។

គាត់គឺជាឆ្មបអាជីព។ ជាថ្មីម្តងទៀតអ្នកដាក់ពាក្យសុំ ត្រូវទទួលការងារកាន់តែធ្ងន់ធ្ងរ ដោយសារតែគាត់យំភ្លាមៗពេលដឹងថា ម្តាយរបស់ខ្លួនត្រូវគេចាប់ខ្លួន។ នៅពេលនោះប្អូនប្រុសរបស់គាត់ឈ្មោះ ផាត់ អុល បានស្លាប់ដោយសារអត់អាហារ។ នៅពេលរបបដួលរលំទៅ គាត់បានបាត់បងសាច់ញាតិចំនួនប្រាំបីនាក់[95]។

(៩) នៅក្នុងឆ្នាំ១៩៧៥ លីម ស៊ាងគាង (11-VSS-00020) និងគ្រួសាររបស់គាត់ រស់នៅក្នុងភូមិគោកគ្រាម ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ក្រោយពេលខ្មែរក្រហមចូលកាន់កាប់ហើយ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសារ ត្រូវបានបញ្ជូនទៅធ្វើការងារ នៅតាមទីកន្លែងផ្សេងៗចំនួនប្រាំមួយ នៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយបន្ទាប់មកបានត្រឡប់ មកស្រុកកំណើតវិញ។ ការងារគឺហត់នឿយខ្លាំងណាស់៖ កាប់គាស់ដើមឈើ និងធ្វើស្រែទាំងថ្ងៃទាំងយប់ ដោយទទួលបានត្រឹមបបរពោត ឬបបរអង្ករហូបប៉ុណ្ណោះ។ នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមមកពីភូមិភាគនិរតី បានចុះឈ្មោះក្រុមគ្រួសារគាត់ យកទៅរៀនសូត្រក្រោមការឃ្លាំមើលដោយមេកងថ្មី បន្ទាប់ពីមេកងចាស់ត្រូវបានគេសម្លាប់។ ជាសំណាងដែរ ដោយមេកងថ្មីឈ្មោះ អ៊ឹម ស្គាល់ប្តីរបស់គាត់ ទើបគ្រួសាររបស់គាត់បានរួចខ្លួនវិញ។ នៅដើមឆ្នាំ១៩៧៧ មេកងបានបញ្ជាឲ្យក្រុមគ្រួសារគាត់ ទៅរែងគ្រួសនៅវត្តត្បូង ក្នុងភូមិប្រាសាទ ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បីខែក្រោយមក ខ្មែរក្រហមប៉ុនប៉ងសម្លាប់ក្រុមគ្រួសាររបស់គាត់ ប៉ុន្តែសម្លេងកាំភ្លើងបានផ្ទុះឡើង ទើបធ្វើឲ្យក្រុមគ្រួសារគាត់ និងអ្នកភូមិដទៃទៀត មានឱកាសរត់គេចមកព្រៃបឹង ក្នុងឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ពួកខ្មែរក្រហមចាប់ផ្តើមចាប់សាច់ញាតិរបស់គាត់ ដោយចោទប្រកាន់ថាពួកគាត់ ជាប់ទាក់ទងនឹង “ប្រជាជន១៧មេសា”។ នៅក្នុងឆ្នាំ១៩៧៧ មីងនិងពូរបស់គាត់ឈ្មោះ គីម និងទៀង រួមជាមួយកូនៗប្រាំមួយនាក់ ត្រូវបានគេសម្លាប់ដោយសារតែ ពួកគាត់ជាប្រជាជន១៧មេសា។ ពូមីងពីរគូទៀតរបស់អ្នកដាក់ពាក្យសុំ រួមជាមួយកូនៗ ត្រូវបានគេសម្លាប់

---

[95] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/805** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផាត់ ហាន ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ នៅត្រង់ 00484884-85។

នៅពេលក្រោយ។ បងប្រុសពីរនាក់របស់អ្នកដាក់ពាក្យសុំ ឈ្មោះ ជាវ និង ភៀវ និងក្រុមគ្រួសារពួកគាត់ ត្រូវបានគេសម្លាប់ផងដែរ[96]។

(១០) ម្តាយរបស់ ទេព ចាន់រ៉ា (11-VSS-00226) បានប្រាប់គាត់ថា នៅក្នុងឆ្នាំ១៩៧៥ បងប្រុសទាំងប្រាំនាក់របស់គាត់ និងបងថ្លៃស្រីម្នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន ហើយបង្ខំឲ្យធ្វើជាកងទ័ពខ្មែរក្រហម។ បងប្រុសម្នាក់ឈ្មោះ ឆេន គឺជាព្រះសង្ឃគង់នៅវត្តព្រៃគគី ក្នុងភូមិត្រពាំងបុណ្យ ឃុំព្រៃគគី ស្រុកចន្ត្រា ខេត្តស្វាយរៀង នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ប៉ុន្តែខ្មែរក្រហមបានចាប់ផ្សឹកលោក រួមជាមួយព្រះសង្ឃដទៃផ្សេងទៀតនៅក្នុងវត្ត ក្រោយពេលពួកវាចូលកាន់កាប់។ នៅក្នុងឆ្នាំ១៩៧៥នេះដែរ ក្រុមគ្រួសាររបស់គាត់ត្រូវបានជម្លៀសដោយបង្ខំ ទៅភូមិដូនទៃ ឃុំទួលស្តី ស្រុកចន្ត្រា ខេត្តស្វាយរៀង។ ក្រោយមកគឺនៅក្នុងឆ្នាំ១៩៧៨ ក្រុមគ្រួសាររបស់អ្នកដាក់ពាក្យសុំ និងអ្នកភូមិដទៃផ្សេងទៀតទាំងអស់ ត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំ ទៅទិសខាងលិច ហើយគេបញ្ជូនប្រជាជនមកពីភូមិភាគនិរតីមកជំនួសវិញ។ នៅក្នុងពេលជម្លៀសដោយបង្ខំនេះ បងប្រុសប្រាំនាក់ និងបងថ្លៃស្រីម្នាក់របស់អ្នកដាក់ពាក្យសុំ ដែលជាកម្មាភិបាលខ្មែរក្រហម បានបែកចេញពីក្រុមគ្រួសារ ហើយបាត់ខ្លួនលែងឃើញជារៀងរហូត។ សមាជិកគ្រួសារដទៃទៀត ត្រូវបានជម្លៀសដោយបង្ខំជាច្រើនលើកច្រើនសារ ដោយសារតែមានការវាយប្រយុទ្ធជាមួយវៀតណាម។ នៅអំឡុងពេលនោះដែរ សាច់ញាតិរបស់អ្នកដាក់ពាក្យសុំឈ្មោះ វង្ស ផែន និងប្រពន្ធកូនរបស់គាត់ ត្រូវបានគេជម្លៀសដោយបង្ខំ ពីខេត្តស្វាយរៀង ទៅខេត្តបាត់ដំបង ហើយក៏បាត់ខ្លួន[97]។

35. ម្ចាស់បណ្តឹងឧទ្ធរណ៍ ដូចមានរាយនាមក្នុងឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីគោលនយោបាយ កំណត់គោលដៅ នៃសហឧក្រិដ្ឋកម្មរួម ក) សុទ្ធតែបានផ្តល់ព័ត៌មានគ្រប់គ្រាន់ទាំងអស់គ្នា ដើម្បីបង្ហាញពីសមាជិកភាពរបស់ពួកគាត់ នៅក្នុងក្រុមឬសហគមន៍ ដែលបានកំណត់គោលដៅជាក់លាក់មួយឬ ច្រើន ដូចមានកំណត់នៅក្នុង

[96] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/228** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លឹម ស៊ាងគាង ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ នៅត្រង់ 00552401-03។

[97] សូមមើល សំណុំរឿង ០០៤ ឯកសារ **D5/165** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទេព ចាន់រ៉ា ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ នៅត្រង់ 00397969-70។

ដីកាសន្និដ្ឋាន។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះគួរបដិសេធ ដីកាស្ដីពីភាពអាចទទួលយកបាន ហើយទទួលស្គាល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ទាំងអស់នេះ ជាដើមបណ្ដឹងរដ្ឋប្បវេណី។

**៣. ដីកាស្ដីពីភាពអាចទទួលយកបាន មានកំហុសអង្គច្បាប់ និងអង្គហេតុបន្ថែមទៀត ដោយសារដកចេញនូវជនរងគ្រោះ ដែលទាក់ទងដោយផ្ទាល់ជាមួយ ឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

36. ជារឿងមិនអាចពន្យល់បាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន ត្រូវបានចាត់ទុកថាមិនអាចទទួលស្គាល់បាន បើទោះបីជាបានទទួលរងព្យសនកម្ម ដែលកើតចេញពីគោលនយោបាយ និងឧក្រិដ្ឋកម្មដែលអាចដាក់បន្ទុកទៅលើ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងជាក់លាក់ទាំងប្រាំមួយ នៅក្នុងភូមិភាគនិរតី នៅអំឡុងពេលដែលគាត់ ប្រើប្រាស់សិទ្ធិអំណាចក្នុងតំបន់ទាំងអស់នោះ។ ដូចដែលបានរៀបរាប់លម្អិត នៅក្នុងឧបសម្ព័ន្ធ ឃ (អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មដោយសារការប្រព្រឹត្ត នៅភូមិភាគនិងទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៤) ម្ចាស់បណ្ដឹងឧទ្ធរណ៍៦៦រូប បានបំពេញតាមលក្ខណៈវិនិច្ឆ័យន័យចង្អៀត (និងខុសឆ្គង) ផ្ទាល់ របស់ដីកាស្ដីពីភាពអាចទទួលយកបានសម្រាប់ការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី។

37. បន្ថែមលើនេះ បើទោះបីជាមិនបានរៀបរាប់ជាក់លាក់ ថាជាទីតាំងមួយក្នុងចំណោមទីតាំងទាំងប្រាំមួយ នៅក្នុងភូមិភាគនិរតីក្ដី តែអ្នកដាក់ពាក្យសុំចំនួន២៦៨រូប បានទទួលរងព្យសនកម្ម នៅក្នុងភូមិភាគនិរតី នៅតាមតំបន់ដែល យឹម ទិត្យ មានសិទ្ធិអំណាចគ្រប់គ្រង ដែលដូច្នេះហើយគួរត្រូវបានទទួលស្គាល់ថាជាដើមបណ្ដឹងរដ្ឋប្បវេណី ផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យចង្អៀតផ្ទាល់ របស់ដីកាស្ដីពីភាពអាចទទួលយកបាន ដែលពិនិត្យមើលជាពិសេស "ទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលការចោទប្រកាន់អំពីព្យសនកម្មរបស់ពួកគាត់ មិនចាំបាច់ទាល់តែកើតឡើងពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅទីតាំង ដែលបានកំណត់ក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬនៅក្នុងដីកាដំណោះស្រាយនោះទេ"[98]។

[98] ដីកាស្ដីពីភាពអាចទទួលយកបាន នៅត្រង់ កថាខណ្ឌ ៣៥ *ដកស្រង់* សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤៩, ៦៦, ៦៨, ៦៩-៧២, ៧៧។

38. យឹម ទិត្យ មានអំណាចធំទូលាយ ទាំងនៅក្នុងគណៈកម្មាធិការតំបន់១៣ និងស្រុកគីរីវង្ស នៃភូមិភាគនិរតី។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានចោទប្រកាន់ថា យឹម ទិត្យ គឺជាអនុលេខា ហើយក្រោយមកជាលេខាគណៈកម្មាធិការស្រុកគីរីវង្ស ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងស្រុង ហើយគាត់ស្ថិតនៅក្នុងគណៈកម្មាធិការតំបន់១៣ ហើយបន្ទាប់មកដឹកនាំគណៈកម្មាធិការនេះ ចាប់តាំងពីឆ្នាំ១៩៧៦ រហូតដល់ពេលដួលរលំនៃរបបនេះ[99]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ថា ដោយមិនគិតអំពីតួនាទីផ្លូវការរបស់គាត់ នៅក្នុងតំបន់ទាំងអស់នេះ យឹម ទិត្យ មានសិទ្ធិអំណាចជាក់ស្តែងធំទូលាយ មិនមែនតែត្រឹមក្នុងស្រុកគីរីវង្ស ឬតំបន់១៣ ប៉ុណ្ណោះទេ គឺនៅក្នុង "ភូមិភាគនិរតីទាំងមូល"[100]។ ការណ៍នេះត្រូវបានគាំទ្រដោយ ការពិតដែលថា គាត់ធ្វើដំណើរគ្រប់កន្លែង ទទួលខុសត្រូវហួសពីតួនាទីផ្លូវការរបស់គាត់ ហើយត្រូវបានមនុស្សជាតិច្រើន មើលឃើញថា គាត់មានតួនាទីជាតំណាងឲ្យតាម៉ុក ជាលេខាភូមិភាគនិរតី ហើយក្រោយមកភូមិភាគពាយ័ព្យ[101]។ សាក្សីបានរាយការណ៍ថា ជាញឹកញាប់គេឃើញ យឹម ទិត្យ ធ្វើដំណើរនៅទូទាំងភូមិភាគ ចូលរួមការប្រជុំកម្រិតភូមិភាគ ទទួលស្វាគមន៍ភ្ញៀវ និងអ្នកមកទស្សនកិច្ច ព្រមទាំងចុះត្រួតពិនិត្យការដ្ឋាន រួមជាមួយតាម៉ុក[102]។ មានគេឃើញថា យឹម ទិត្យ ធ្វើការនៅមន្ទីរភូមិភាគនិរតី ហើយមានការលើកឡើងថា គាត់ទទួលខុសត្រូវលើមុខងារ កម្រិតភូមិភាគមួយចំនួនទៀត ដូចជាកងនិរសាភូមិភាគ និងគ្រប់គ្រងលើការផ្គត់ផ្គង់ភូមិភាគ[103]។ ទោះបីជាពេលផ្លាស់ពីភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យហើយក្តី ប៉ុន្តែដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ថា យឹម ទិត្យ ធ្វើដំណើរជាញឹកញាប់ទៅមក និងប្រើប្រាស់ "សិទ្ធិអំណាច និងការទទួលខុសត្រូវព្រមគ្នា នៅក្នុងភូមិភាគទាំងពីរ"[104]។ សរុបមកដើម្បីគោរពតាម យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ លើបញ្ហាមួយនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលទទួលរងព្យសនកម្ម ដែលជាផលវិបាកផ្ទាល់ នៃគោលនយោបាយកម្រិតជាតិទាំងបួន ដែលអនុវត្តឡើងដើម្បីជម្រុញដល់ ផែនការឧក្រិដ្ឋកម្មរួម នៃសហឧក្រិដ្ឋកម្មរួម ក (ផ្នែក

---

[99] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣២៧-៣៣២។

[100] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៤៨-៣៥០។ សូមមើលផងដែរ heading preceding កថាខណ្ឌ ៣៤៨។

[101] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៣២, ៣៣៤-៣៣៥។

[102] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៤៨-៣៥០។

[103] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៥០។

[104] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៥២។

V(ក)(១) ខាងលើ) ព្រមទាំងអ្នកដែលទទួលរង ការខូចខាតជាសម្ភារភាព ក្នុងនាមជាជនរងគ្រោះនៃ សហគមន៍ឬក្រុមគោលដៅជាក់លាក់ (ផ្នែក V(ខ)(២) ខាងលើ) គួរត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី។ ទីតាំងនៃព្យសនកម្ម របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងទីតាំងឧក្រិដ្ឋកម្ម និង/ឬភូមិភាគ ដែលមានកំណត់នៅក្នុង ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់នូវទំនាក់ទំនងបន្ថែមទៀត រវាងព្យសនកម្មពួកគាត់ និងសកម្មភាពឧក្រិដ្ឋរបស់ យឹម ទិត្យ។ ដូចដែលបានរៀបរាប់លម្អិត នៅក្នុងឧបសម្ព័ន្ធ ឃ (អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មដោយសារការប្រព្រឹត្ត នៅភូមិភាគនិងទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៤) ម្ចាស់បណ្តឹងឧទ្ធរណ៍ចំនួន៦៦រូប ទទួលរងការខូចខាត ដែលបណ្តាលមកពីគោលនយោបាយ និងឧក្រិដ្ឋកម្ម ដែលអាចដាក់បន្ទុកទៅលើ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ និងទីតាំងជាក់លាក់ទាំងប្រាំមួយ នៅក្នុងភូមិភាគនិរតី ហើយម្ចាស់បណ្តឹងឧទ្ធរណ៍ ២៦៨ រូបទៀត ទទួលរងការខូចខាត ដែលបណ្តាលមកពីគោលនយោបាយ និងឧក្រិដ្ឋកម្ម ដែលអាចដាក់បន្ទុកទៅលើ យឹម ទិត្យ នៅទូទាំងភូមិភាគនិរតី។

## ខ. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍៖ អង្គហេតុដែលបានដកចេញ ពីការស៊ើបអង្កេត អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង អាចត្រូវបានយកមកពិចារណា ក្នុងការសម្រេចលើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី

39. តាមរយៈការកម្រិតវិសាលភាពភូមិសាស្ត្រ នៃភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញនូវជនរងគ្រោះ ដែលអាចត្រូវបានទទួលយក នៅមុនពេលមាន*សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង*។ លទ្ធផលនេះគឺផ្ទុយគ្នាជាមួយការបញ្ជាក់ជាក់ច្បាស់ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន និងដីកាសម្រេចមុនៗ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ដែលថាការកាត់បន្ថយវិសាលភាព នៃការស៊ើបសួរ គឺមិនមានអនុភាពចំពោះភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនោះ[105]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការបដិសេធ មិន

[105] សូមមើលដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៩( "អង្គហេតុដែលបានដកចេញ ផ្អែកលើមូលដ្ឋាននៃវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ដែលអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅតែអាចបង្កើតជាមូលដ្ឋាន សម្រាប់សេចក្តីសម្រេចលើភាពអាចទទួលយកបាន ប្រសិនបើអ្នកដាក់ពាក្យសុំ បានបំពេញនូវលក្ខខណ្ឌដែលនៅសល់"។

ពិចារណាទៅលើឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង០០៤ ដែលកើតឡើងនៅក្រៅភូមិភាគពាយ័ព្យ ឬទីតាំងជាក់លាក់ទាំងប្រាំមួយ នៅក្នុងភូមិភាគនិរតី ដែលប្រការនេះបណ្តាលឱ្យមាន ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើ ម្ចាស់បណ្តឹងឧទ្ធរណ៍។

40. នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានចេញ *សំណើសុំមតិយោបល់ ទាក់ទងអង្គហេតុដែលត្រូវបានចោទប្រកាន់ តែមិនត្រូវបានស៊ើបអង្កេតបន្ត* ដោយគូសបញ្ជាក់ពីអង្គហេតុចំនួនដប់បី ដែលត្រូវបានចោទប្រកាន់នៅក្នុង ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលចៅក្រមមិនមានចេតនា ក្នុងការស៊ើបអង្កេតបន្ថែម[106]។ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ *ដីកាសម្រេចកាត់បន្ថយ វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង* ដែលក្នុងដីកានោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញនូវការចោទប្រកាន់លើអង្គហេតុ ដោយអនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ទាក់ទងនឹង (ក) ទីតាំងសម្លាប់មនុស្សដំណាក់វាំង (ខ) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្ហត (គ) ទីតាំងនៅតំបន់៥ ភូមិភាគពាយ័ព្យ[107] (ឃ) អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ (ង) ការដ្ឋានភ្នំត្រជាក់ចិត្ត (ច) ទីតាំងសម្លាប់មនុស្ស បន្ទាយអូរតាគ្រី (ឆ) មន្ទីរសន្តិសុខវត្តកណ្តាល (ជ) មន្ទីរសន្តិសុខវត្តបន្ទាយនាង (ឈ) មន្ទីរសន្តិសុខវត្តធម្មយុត[108]។ តាមវិធាន ៦៦ ស្ទួន (៣) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ត្រូវតែសម្រេចពីផលប៉ះពាល់ នៃសេចក្តីសម្រេចក្នុងការកាត់បន្ថយ វិសាលភាពនៃកិច្ចស៊ើបសួរ តាមផ្លូវតុលាការទៅលើ "ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិ

[106] សំណុំរឿង ០០៤ ឯកសារ **D302** សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុ ដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៧, ១០ (ច្រានចោលអង្គហេតុទី១ ដល់ទី១៣ ហើយអញ្ជើញភាគីឱ្យដាក់សារណា លើកឡើងថាតើ ភាគីពិចារណាថាការដកចេញនេះ គោរពតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែរឬទេ និង/ឬ ថាតើការអនុវត្តវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ជាការសមស្របដែរឬទេ)។

[107] ទីតាំងទាំងនោះគឺ៖ ការដ្ឋាន និងមន្ទីរសន្តិសុខភ្នំត្រយង, ការដ្ឋានទំនប់ព្រៃរនាម និងស្ពានស្រែង, ទីតាំងសម្លាប់មនុស្ស និងឃុំឃាំងមនុស្សវត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ, មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភ្នំចក្រី, ទីតាំងសម្លាប់មនុស្សព្រៃតារ៉ុត, ទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ និងការដ្ឋានទំនប់ត្រពាំងថ្ម។ សូមមើល សំណុំរឿង ០០៤ ឯកសារ **D359** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ៤។

[108] សំណុំរឿង ០០៤ ឯកសារ **D359** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ១៥។

របស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរ”[109]។ ការធ្វើដូច្នេះគឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់យ៉ាងជាក់ច្បាស់ថា ការដកចេញនូវអង្គហេតុខាងលើ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង នឹង “មិនប៉ះពាល់ដល់ឋានៈរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ឬសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ”[110]។ ដីកាស្តីពីភាពអាចទទួលយកបាន បានបញ្ជាក់ប្រហែលគ្នាថា អង្គហេតុដែលបានដកចេញ ដោយផ្អែកលើមូលដ្ឋាននៃវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង “អាចនៅតែជាមូលដ្ឋាន នៃដីកាសម្រេចលើភាពអាចទទួលស្គាល់ ជាដើមបណ្តឹងរដ្ឋប្បវេណី”[111]។

41. ទោះបីជាមានការបញ្ជាក់ម្តងហើយម្តងទៀតថា ដីកាសម្រេចតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង មិនប៉ះពាល់ដល់ឋានៈ ជាដើមបណ្តឹងរដ្ឋប្បវេណីក្តី ប៉ុន្តែដីកាស្តីពីភាពអាចទទួលយកបាន បានកម្រិតទៅលើភាពអាចទទួលយក ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ តែចំពោះ “អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម នៅភូមិភាគពាយ័ព្យ រវាងពីដើមឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[112] “អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម ដោយសារផែនការរួមទូទាំងប្រទេស ដែលបានដាក់ជាបទចោទ អនុវត្តយ៉ាងហោចណាស់ពីឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីលុបបំបាត់ខ្មែរក្រោមទាំងស្រុង ឬមួយផ្នែក”[113] “អ្នកដាក់ពាក្យសុំដែលបានទទួលរង ព្យសនកម្មដោយសារឧក្រិដ្ឋកម្មណាមួយ... ដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ យ៉ាងហោចណាស់រវាងខែកញ្ញា-តុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[114] និង “អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម ... នៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខវត្តក្រាំងតាចាន់ ទីកន្លែងសម្លាប់មនុស្សភូមិព្រៃល ទីកន្លែងសម្លាប់មនុស្សវត្តអង្គញដី ទីកន្លែងសម្លាប់មនុស្សភូមិព្រៃស្តែង ឬព្រៃសុខុន និងទីកន្លែងសម្លាប់មនុស្សវត្តអង្គសិរីមុនី”[115]។ ប៉ុន្តែ វិសាលភាព

---

[109] វិធាន ៦៦ ស្ទួន (៣) នៃវិធានផ្ទៃក្នុង។

[110] សំណុំរឿង ០០៤ ឯកសារ **D2359** ដីកាសម្រេចកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ១៤។

[111] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៩។

[112] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៧។

[113] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៨(ក)។

[114] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៨(ខ)។

[115] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៨(គ)។

ពេញលេញនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ ពីដើមដំបូងនៅក្នុងសំណុំរឿង ០០៤ គ្របដណ្តប់លើទីតាំងភូមិសាស្ត្រធំខ្លាំងជាងនេះ។ សេចក្តីសម្រេចក្នុងការកម្រិតភូមិសាស្ត្រ ទៅលើភាពអាចទទួលយក ជាដើមបណ្តឹងរដ្ឋប្បវេណី បានរារាំងប្រកបដោយប្រសិទ្ធិភាព ដល់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីមុន មិនឱ្យពួកគេបន្តចូលរួម ក្នុងកិច្ចដំណើរការនីតិវិធី។

42. ជាឧទាហរណ៍ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ង (អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថា មិនអាចទទួលស្គាល់បាន ដោយសារតែការកាត់បន្ថយវិសាលភាពការជំនុំជម្រះ) ដីកាស្តីពីភាពអាចទទួលយកបាន បានប្រកាសថាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនដប់នាក់ គឺមិនអាចទទួលយកបានទេ បើទោះបីជាមានភស្តុតាងដែលបង្ហាញថា អ្នកដាក់ពាក្យសុំទាំងអស់នេះ បានទទួលរងព្យសនកម្ម នៅការដ្ឋានទំនប់ត្រពាំងថ្ម ជាទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធ ដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ហើយដែលនៅពេលបន្ទាប់មក ត្រូវបានដកចេញពីដីកាសម្រេច តាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[116]។

43. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាពីការចោទប្រកាន់ជាទ្រង់ទ្រាយធំ នៅក្នុងសំណុំរឿងដើមប្រឆាំងនឹង យឹម ទិត្យ ឡើយ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិចារណាតែទៅលើអ្នកទាំងឡាយណា ដែលគាត់ពិចារណាថាស្ថិតនៅក្នុងវិសាលភាព ដែលបានកម្រិតកំណត់ជាថ្មី របស់សំណុំរឿង០០៤។ សិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៤ មិនអាចត្រូវបានបដិសេធចោល ដោយសារតែមូលដ្ឋានបែបនេះឡើយ។ ការសម្រេចផ្ទុយពីនេះ គឺអនុញ្ញាតឱ្យមានការអនុវត្តនីតិវិធីជាធម្មតា ក្នុងគោលបំណងពន្លឿនកិច្ចដំណើរការនីតិវិធី គឺបានដកហូតសិទ្ធិជនរងគ្រោះ ក្នុងការចូលរួមប្រកបដោយប្រសិទ្ធិភាព នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្ម និងគោលនយោបាយ ដែលត្រូវបានចោទប្រកាន់ ដែលបានធ្វើឱ្យពួកគេទទួលរង នូវព្យសនកម្មយ៉ាងធំធេង។

[116] ម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងដប់រូបរួមមាន៖ វិញ សាម៉ិញ (13-VSS-00026) មុ សាមៃ (13-VSS-00057) ជិន សាវ៉ៃ (13-VSS-00073) ឃុត ខុញ (13-VSS-00085) ឈឹម សំពៀង (13-VSS-00542) ពឹក អៀប (13-VSS-00543) ម៉ុះ គីមឆាត (13-VSS-00545) ខ្មែក ប៉ាច (13-VSS-00548) ជ្រូក ភ័ស (13-VSS-00335 ) និង អោម ឆៃឡាង (13-VSS-00358)។

44. បន្ថែមលើនេះ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីផលប៉ះពាល់នៃការកាត់បន្ថយ វិសាលភាពនៃកិច្ចស៊ើបសួរ គឺប្រឆាំងទៅនឹងសិទ្ធិរបស់ជនរងគ្រោះ ដែលតម្រូវឱ្យតុលាការមាន ទស្សនៈទូលំទូលាយចំពោះភាពអាចទទួលយកបាន ជាដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា បើតាមគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក វិធានផ្ទៃក្នុងត្រូវតែបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ[117]។ ជាពិសេសដោយផ្អែកលើគោលដៅនៃការបង្រួបបង្រួមជាតិរបស់ អ.វ.ត.ក អង្គជំនុំជម្រះ និងចៅក្រមរបស់ អ.វ.ត.ក "ត្រូវតែយកចិត្តទុកដាក់ជាពិសេស និងធានានូវការចូលរួម ប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ នៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត"[118]។ ដីកាស្ដីពីភាពអាចទទួលយកបាន បានអនុវត្តផ្ទុយពីគោលដៅនេះយ៉ាងច្បាស់ក្រឡែត ដោយកម្រិតមិនសមហេតុផល ទៅលើវិសាលភាពនៃភាពអាចទទួលយកបាន ជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤។

45. ដោយផ្អែកលើការបកស្រាយខាងលើ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំដល់អង្គបុរេជំនុំជម្រះសម្រេចថា ដីកាស្ដីពីភាពអាចទទួលយកបាន បានបដិសេធដោយខុសឆ្គង ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានកំណត់អត្តសញ្ញាណ នៅក្នុងឧបសម្ព័ន្ធ ខ (ឧបសម្ព័ន្ធ ង៖ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថា មិនអាចទទួលស្គាល់បាន ដោយសារតែការកាត់បន្ថយ វិសាលភាពការជំនុំជម្រះ) ដែលពួកគាត់បានទទួលរងព្យសនកម្ម ដែលជាផលវិបាកនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សដំណាក់វាំង, ការដ្ឋានទំនប់កង្ហត, មន្ទីរសន្តិសុខនិងការដ្ឋានភ្នំត្រយង, ការដ្ឋានទំនប់ត្រពាំងថ្ម និងអន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ និងទីបី ដែលក្រោយមកត្រូវបានដកចេញ តាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង។

---

[117] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[118] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។ សូមមើលផងដែរ សេចក្ដីសន្និដ្ឋានបឋម *ខាងលើ*។

## គ. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងអង្គច្បាប់ ដោយមិនបានផ្តល់សេចក្តីសម្រេច ដោយមានសំអាងហេតុ សម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

46. ដីកាស្តីពីភាពអាចទទួលយកបាន មិនបានបំពេញតាមបទដ្ឋានអប្បបរមា ដែលអង្គបុរេជំនុំជម្រះបានកំណត់ សម្រាប់សេចក្តីសម្រេចដែលមានសំអាងហេតុ។ អង្គបុរេជំនុំជម្រះបានរំឮក ដល់សហចៅក្រមស៊ើបអង្កេតថា សហចៅក្រមស៊ើបអង្កេតត្រូវតែចេញ ដីកាសម្រេចដោយមានសំអាងហេតុ សម្រាប់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីគោរពដល់គោលការណ៍នីត្យានុកូលភាពជាសារវន្ត ដែលរួមមានតម្លាភាព និងសច្ចភាពផ្លូវច្បាប់[119]។ បើទោះបីជាសហចៅក្រមស៊ើបអង្កេត មិនចាំបាច់ត្រូវរៀបរាប់លម្អិត កត្តាទាំងអស់នៅក្នុងដំណើរការសម្រេចរបស់ខ្លួនក្តី ប៉ុន្តែយ៉ាងហោចណាស់ក៏សហចៅក្រមស៊ើបអង្កេត ត្រូវតែ "បង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច"[120]។ ជាពិសេស សិទ្ធិក្នុង

---

[119] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧ ដល់៣៨។ ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលរបស់ តុលាការ ICTY បានសម្រេចថា សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ គឺជាធាតុផ្សំនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងថា មានតែផ្អែកទៅលើមូលដ្ឋាននៃសេចក្តីសម្រេច ដោយមានសំអាងហេតុប៉ុណ្ណោះ ទើបការត្រួតពិនិត្យសមស្របនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អាចធ្វើទៅបាន។សូមមើល រដ្ឋអាជ្ញា តទល់នឹង *Momir Nikolic* សាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងការផ្តន្ទាទោស ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៦ សំណុំរឿង IT-02-60/1-A កថាខណ្ឌ ៩៦។ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ ICTY បានសម្រេចថា "ជាកម្រិតអប្បបរមា អង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវតែផ្តល់សំអាងហេតុ ដើម្បីគាំទ្រដល់ការសម្រេចរបស់ខ្លួន ទាក់ទងការពិចារណាលើអង្គសេចក្តី ពាក់ព័ន្ធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ"។ រដ្ឋអាជ្ញា តទល់នឹង *Milutinovic និងអ្នកដទៃទៀត* សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំ លើដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោះលែង Nebojsa Pavkovic បណ្តោះអាសន្ន ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៥។ រឿងក្តី IT-05-87-AR65.1, កថាខណ្ឌ ១១។ សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង *Lubanga*, ICC-01/04-01/06 -774 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ១ ដែលមានចំណងជើងថា "ដីកាសម្រេចលើកទីពីរ លើសំណើររបស់រដ្ឋអាជ្ញា និងសំណើដែលបានកែតម្រូវសម្រាប់ការកោសលុប តាមវិធាន ៨១" ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០៖ "ដោយផ្អែកទៅលើមូលដ្ឋាននៃសចក្តីសម្រេចដោយមានសំអាងហេតុប៉ុណ្ណោះ ទើបការត្រួតពិនិត្យសមស្រប នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អាចធ្វើទៅបាន"។

[120] សំណុំរឿង ០០២ ឯកសារ **D411/3/6**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍

ការទទួលបានការពិនិត្យ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ដែលមានចែងក្នុងវិធានផ្ទៃក្នុង នឹងទៅជាគ្មានន័យ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី មិនទទួលបាននូវសំអាងហេតុនៃដីកាសម្រេច ដែលពួកគេប្តឹងឧទ្ធរណ៍នោះ។ ក្នុងន័យប្រហែលគ្នានេះ អង្គបុរេជំនុំជម្រះនឹងមិនអាចធ្វើការពិនិត្យឡើងវិញឲ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាព ទៅលើបណ្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសម្រេចបដិសេធ ដោយមិនមានការយល់ដឹងគ្រប់គ្រាន់ អំពីសំអាងហេតុជាមូលដ្ឋាននោះបានទេ ប្រសិនបើមាន[121]។

47. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនគោរពតាមលក្ខខណ្ឌតម្រូវ នៃសេចក្តីសម្រេចដោយមានសំអាងហេតុ[122]។ ក្នុងករណីនោះ សហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គងដោយបានបដិសេធ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានទូទៅដូចជា "ទំនាក់ទំនងហេតុនិងផលចាំបាច់ រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ"[123]។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា តារាងឧបសម្ព័ន្ធដែលមានសំអាងហេតុបន្ថែម របស់សហចៅក្រមស៊ើប

---

ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩។

[121] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៨។

[122] សំណុំរឿង ០០២ ឯកសារ **D411/3/6**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

[123] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

អង្កេត សម្រាប់អ្នកដាក់ពាក្យសុំម្នាក់ មានយ៉ាងច្រើនបំផុតពីរឃ្លា ដែលឃ្លានីមួយៗមាន ០៥ទៅ ១៥ពាក្យ ហើយខ្លឹមសារ មិនមានភាពជាក់លាក់ ចំពោះអ្នកដាក់ពាក្យសុំនីមួយៗនោះទេ[124]។

48. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តក្នុងអានុភាពដូចគ្នា ចំពោះដីកាស្តីពីភាពអាចទទួលយកបាននៅទីនេះ។ កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតជាតិ បានបញ្ចប់នៅត្រឹមកម្រិតផ្នែកយុត្តាធិការ ដោយពុំបានធ្វើការវាយតម្លៃណាមួយ ទៅលើអង្គសេចក្តីជាមូលដ្ឋាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចទៅលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបានច្រានចោលពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនលើសលប់ជារួម ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវ លើពាក្យសុំនីមួយៗនោះឡើយ។ ដូចនៅក្នុងសំណុំរឿង០០២ដែរ សំអាងហេតុនៃការបដិសេធ គឺមានត្រឹមតែពីរបីឃ្លាខ្លីៗ ជាឃ្លាដែលគេយកមកប្រើប្រាស់ឡើងវិញ ឬមិនមានសំអាងហេតុផងក៏សឹងមាន។ ជាពិសេស ដីកាស្តីពីភាពអាចទទួលយកបាន បានបដិសេធជិតពីរភាគបី នៃម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានជាទូទៅថា (ក) អង្គហេតុដែលបានរៀបរាប់ "ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង" (ខ) មិនបានបង្ហាញថា "ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់"[125]។ មានបីករណីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គ្រាន់តែបញ្ជាក់ឡើងវិញអំពីអង្គហេតុ ដោយមិនមានបង្ហាញសំអាងហេតុ សម្រាប់ការបដិសេធ[126]។ ដីកាស្តីពីភាពអាចទទួលយកបាន មិនបានផ្តល់ការបញ្ជាក់បំភ្លឺណាមួយឡើយ អំពីអត្ថន័យនៃមូលដ្ឋានទាំងអស់នេះក្នុងការបដិសេធ ឬថាតើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថាខ្វះខាតអ្វីជាក់លាក់នៅក្នុងពាក្យសុំតាំងខ្លួននោះ។ កង្វះភាពជាក់លាក់ពាក់ព័ន្ធនឹងសំអាងហេតុ សម្រាប់ការបដិសេធ

[124] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

[125] សំណុំរឿង ០០៤ ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩។

[126] ករណីទាំងអស់នេះរួមមាន អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន (12-VSS-00582) ញឹម កុល (12-VSS-00672) និង អ៊ី ម៉យ (13-VSS-00707)។

អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនេះ មិនអាចឲ្យម្ចាស់បណ្តឹងឧទ្ធរណ៍ អនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួន ប្រកបដោយអត្ថន័យនោះឡើយ។

49. ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ច (មូលដ្ឋានសម្រាប់ការសម្រេច លើភាពមិនអាចទទួលយកបាន របស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដល់អង្គបុរេជំនុំជម្រះ ច្រានចោលដីកាស្តីពីភាពអាចទទួលយកបាន ក្នុងគ្រប់ករណីដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែ "ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង" (មូលដ្ឋានទី១) ឬក្នុងករណីដែល "មិនត្រូវបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់" (មូលដ្ឋានទី៣) ឬក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់សំអាងហេតុណាមួយ សម្រាប់គាំទ្រដល់ការសម្រេចមិនទទួលយក ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (មូលដ្ឋានទី៩) ដោយផ្អែកលើមូលដ្ឋានថា ការបដិសេធពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ មិនត្រូវបានធ្វើឡើងដោយ ដីកាសម្រេចដែលមានសំអាងហេតុ។

**ឃ. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងលើអង្គច្បាប់ និងអង្គហេតុ ដោយសារបដិសេធលើម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ បើទោះបីជាបានបំពេញតាមបទដ្ឋាន នៃការបង្ហាញភស្តុតាង ដែលបានតម្រូវតាមវិធានផ្ទៃក្នុង និងស្ថានសម្រាលទោសក្តី**

50. ដីកាស្តីពីភាពអាចទទួលយកបាន មានកំហុសឆ្គងក្នុងការបដិសេធអ្នកដាក់ពាក្យសុំ ដែលមិនបាន ផ្តល់ព័ត៌មានគ្រប់គ្រាន់។ ដូចដែលបានរៀបរាប់លម្អិត នៅក្នុងឧបសម្ព័ន្ធ ឆ(១) (ទឡ្ហីករណ៍នៃភាពអាចទទួលយកបាន សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែពុំមានភស្តុតាង ឬមូលដ្ឋានពាក់ព័ន្ធគ្រប់គ្រាន់ (ក្រុមអ្នកច្បាប់ជាតិ-អន្តរជាតិ)) និង ឆ(២) (ទឡ្ហីករណ៍នៃភាពអាចទទួលយកបាន សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែពុំមានភស្តុតាង ឬមូលដ្ឋានពាក់ព័ន្ធគ្រប់គ្រាន់ (ក្រុមអ្នកច្បាប់ជាតិ)) បទដ្ឋានបង្ហាញភស្តុតាង និងភាពគ្រប់គ្រាន់នៃព័ត៌មាន ដែលបានតម្រូវតាមវិធានផ្ទៃក្នុង (បកស្រាយរួមគ្នាជាមួយ

ស្ថានសម្រាលទោស ដែលបានរៀបរាប់លម្អិតដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន) គឺត្រូវបានបំពេញដោយអ្នកដាក់ពាក្យសុំទាំងអស់នោះ។

51. វិធាន ២៣ ស្ទួន (១) និង(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តបានចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវតែមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធានាដល់ការពិនិត្យបញ្ជាក់ អំពីភាពសមស្របជាមួយនឹងវិធានផ្ទៃក្នុង[127]។ ពិសេសទៅទៀតនោះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែមានព័ត៌មានលម្អិតអំពីអត្តសញ្ញាណ និងឋានៈជាជនរងគ្រោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងភស្តុតាងនានាអំពីព្យសនកម្មដែលបានទទួលរង ឬព័ត៌មាន "បង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវបានចោទប្រកាន់"[128]។ ព័ត៌មានត្រូវបានចាត់ទុកថាគ្រប់គ្រាន់ នៅពេលដែលព័ត៌មាននោះអនុញ្ញាតិឲ្យ សហចៅក្រមស៊ើបអង្កេតជឿជាក់បានថា អង្គហេតុដែលបានអះអាង អាចជាការពិត[129]។

52. ដូចដែលបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ វិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង មានកម្មវត្ថុ និងគោលបំណង កំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមែនដាក់កំហិត ឬកម្រិតលើទស្សនៈនៃបណ្តឹង របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅអ.វ.ត.ក ឡើយ[130]។ ការដាក់វិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង នៅក្នុងអនុជំពូកស្តីពីបទប្បញ្ញត្តិទូទៅ នៃជំពូកស្តីពីនីតិវិធី នៃវិធានផ្ទៃក្នុង បានចង្អុលបង្ហាញថា វិធាននេះត្រូវតែបកស្រាយ

---

[127] វិធាន ២៣ ស្ទួន(១) និង(៤) នៃវិធានផ្ទៃក្នុង។ សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២។

[128] វិធាន ២៣ ស្ទួន (៤) នៃវិធានផ្ទៃក្នុង។

[129] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៩៤។

[130] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦២។

ស្របគ្នា ជាមួយវិធាន២១ ដែលកំណត់អំពីករណីយកិច្ចជាសារវន្ត ក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ និងធានាអំពីតម្លាភាព និងសច្ចភាពផ្លូវច្បាប់[131]។

53. សហចៅក្រមស៊ើបអង្កេតត្រូវតែសម្រេចថា តើមានមូលដ្ឋានដែលអាចជឿជាក់បាន*ជាបឋម*ដែរឬទេ ដែលចង្អុលបង្ហាញថាអ្នកដាក់ពាក្យសុំ បានទទួលរងព្យសនកម្ម ដែលទាក់ទងជាមួយអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋាននៃធាតុផ្សំ នៅក្នុងសំណុំរឿង។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ដោយសារតែកម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវដោះស្រាយនៅ អ.វ.ត.ក "ជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាត ដែលបង្កដោយអំពើសាហាវយង់ឃ្នង ជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល ព្រោះការខូចខាតនេះ គ្របដណ្តប់ទៅលើផ្នែកជាបុគ្គលនានា"[132]។ ដោយទទួលស្គាល់ថា អំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ កើតចេញពីគោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ដែលសំដៅទៅលើបុគ្គល ឬក្រុមជាក់លាក់ ព្រមទាំងសហគមន៍ទាំងមូលនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា "ការដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល ត្រូវតែពិនិត្យមើលក្នុងស្ថានភាពពិសេសនៃជម្លោះ"[133]។

54. នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់កត្តាចំនួនបី ដែលសម្រាលភស្តុតាងនៃព្យសនកម្មចាំបាច់ថែមទៀត សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលរួមមាន៖

---

[131] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបឋម *ខាងលើ* ។

[132] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

[133] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

ក. ពេលវេលាកន្លងផុតទៅយូរ និងផលប៉ះពាល់ដែលកត្តានេះ អាចមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំ ក្នុងការផ្តល់ឯកសារភស្តុតាង ពាក់ព័ន្ធនឹងព្យសនកម្មដែលខ្លួនទទួលរង ដូចជាឯកសារពេទ្យ ក្នុងករណីដែលមានការចោទប្រកាន់ អំពីព្យសនកម្មខាងរាងកាយ។

ខ. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានបញ្ហាសមត្ថភាពក្នុងការបង្ហាញ ក្នុងការឆ្លើយតប ឬធ្វើកំណត់ហេតុឲ្យបានស៊ីជម្រៅ និងត្រឹមត្រូវអំពីផលប៉ះពាល់ ដែលស្ថានភាពនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានមកលើសុខភាពផ្លូវចិត្តរបស់ប្រជាជន។

គ. ការជម្លៀស ការប្តូរទីកន្លែង និងការផ្លាស់ទីលំនៅរបស់ប្រជាជន ទៅតាមតំបន់ផ្សេងៗ និងផលប៉ះពាល់ដែលកត្តានេះមាន មកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការផ្តល់ភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិ ក្នុងករណីមានការចោទប្រកាន់ អំពីការបាត់បង់ទ្រព្យសម្បត្តិ និងលទ្ធភាពក្នុងការផ្តល់ភស្តុតាង បញ្ជាក់អំពីប្រាក់ចំណូល ក្នុងករណីមានការចោទប្រកាន់អំពី ការបាត់បង់ប្រាក់ចំណូល[134]។

55. បន្ថែមលើនេះ អង្គហេតុដែលថាសហចៅក្រមស៊ើបអង្កេត មិនបានជូនដំណឹងឲ្យទាន់ពេលវេលា និងបានត្រឹមត្រូវ ទៅដល់ជនរងគ្រោះ នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធី ដែលជាការរំលោភបំពានទៅលើវិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង ក៏ជាកត្តាសម្រាលបន្ថែមមួយទៀតដែរ សម្រាប់ការបង្ហាញភស្តុតាងអំពីព្យសនកម្ម[135]។ ការទទួលបានព័ត៌មាន គឺជាការសំខាន់ជាពិសេស នៅក្នុងដំណាក់កាលមុនការជំនុំជម្រះ សម្រាប់ជនរងគ្រោះដែលអាចស្វែងរក ការសុំចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែជនរងគ្រោះ មិនអាចចូលពិនិត្យមើលសំណុំរឿងបាន ពួកគេត្រូវពឹងផ្អែកទាំងស្រុង ទៅលើព័ត៌មានដែលផ្សព្វផ្សាយ ដោយសហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើការ

---

[134] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៤១។

[135] តាមវិធាន ២១ (១)(គ) នៃវិធានផ្ទៃក្នុង "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី" (ដោយគូសបញ្ជាក់បន្ថែម)។ អង្គបុរេជំនុំជម្រះបានសម្រេចថា ការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងបណ្តុំធំទូលាយនៃសិទ្ធិរបស់ជនរងគ្រោះ ដូចមានចែងនៅក្នុងវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង គឺពាក់ព័ន្ធជាមួយបណ្តឹងឧទ្ធរណ៍ ស្តីពីភាពអាចទទួលយកបាន តាមវិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុង, សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥២ (សង្កត់ធ្ងន់ថា វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង "មិនមានចន្លោះប្រហោងសម្រាប់ការបកស្រាយឡើយ, មិនបាននិយាយថា "ឆាប់ៗតាមអាចធ្វើទៅបាន" ឬ "នៅមុនពេលបញ្ចប់កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ""។

សម្រេចថា តើពួកគេត្រូវដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណីដែរឬអត់។ ត្រង់ចំណុចនេះ បើទោះបីជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រូវបានដាក់នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត មិនបានដាក់បង្ហាញដល់ជនរងគ្រោះ នូវទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនានា រហូតដល់ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ គឺនៅរយៈពេលជិតបីឆ្នាំក្រោយ[136] ហើយ និងមិនបានបញ្ជាក់លម្អិត អំពីទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹង យឹម ទិត្យ រហូតដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥[137]។ សូម្បីតែនៅពេលនោះក្ដី សហចៅក្រមស៊ើបអង្កេត សម្រេចដាក់បង្ហាញនូវព័ត៌មានអំពីទីតាំងឧក្រិដ្ឋកម្ម គ្រាន់តែដើម្បីទប់ស្កាត់ការទាយស្មាន និងព័ត៌មានមិនត្រឹមត្រូវ ដែលបានចែកចាយដោយសារមិនមាន សេចក្ដីថ្លែងការណ៍ជាផ្លូវការ របស់សហចៅក្រមស៊ើបអង្កេត ទៅលើបញ្ហានេះ។ ការធ្វើបែបនេះ គឺសហចៅក្រមស៊ើបអង្កេត បានកត់សម្គាល់យ៉ាងច្បាស់លាស់ អំពី "មន្ទិលសង្ស័យខ្លាំងក្លា" របស់ពួកគាត់ អំពីបញ្ហាថាតើ សំណុំរឿង០០៤ នឹងបន្តទៅមុខដែរឬយ៉ាងណា ដែលការណ៍នេះបង្កនូវការយល់ច្រឡំ និងធ្វើឲ្យបាត់បង់នូវជំនឿ របស់ជនរងគ្រោះចំពោះលទ្ធផល នៃការស៊ើបអង្កេត[138]។ អង្គបុរេជំនុំជម្រះគួរតែពិចារណា អំពីការរំលោភបំពានទៅលើសិទ្ធិ

[136] ការិយាល័យសហចៅក្រមស៊ើបអង្កេត សេចក្ដីប្រកាសរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅ គេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC%20PR%20OCIJ%208%20Aug%202011%20%28Eng%29.pdf ។

[137] សេចក្ដីប្រកាសរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្ដីពីសំណុំរឿង០០៤ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ អាចរកមើលបាននៅ គេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC%20PR%209%20Dec%202015%20Eng.pdf ។

[138] ការិយាល័យសហចៅក្រមស៊ើបអង្កេត សេចក្ដីប្រកាសរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅ គេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC%20PR%20OCIJ%208%20Aug%202011%20%28Eng%29.pdf ("កន្លងមក ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនបានជូនដំណឹងដល់សាធារណជន អំពីទីតាំងឧក្រិដ្ឋកម្ម នៅក្នុងសំណុំរឿង០០៤ឡើយ ដោយសារតែផ្ទុយពីសំណុំរឿង ០០២ គឺមានវិមតិសង្ស័យយ៉ាងខ្លាំងក្លា ចំពោះបញ្ហាថាតើ ជនសង្ស័យគឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬអត់ ទៅតាមលក្ខខណ្ឌតម្រូវ យុត្តាធិការ នៃមាត្រា ២ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។ ប្រសិនបើតុលាការមិនមានយុត្តាធិការទេ គឺជារឿងមិនសមស្របដែលជម្រុញឲ្យមាន ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមលើ ពាក្យសុំតាំងខ្លួនចំនួន២០០ ដែលបានទទួលរួចមកហើយ នៅក្នុងសំណុំរឿងនេះ។ ការធ្វើបែបនេះគឺអាចបង្កើននូវក្ដីរំពឹងទុក ដែលក្រោយមកមិនអាចបំពេញបាន។ ទោះជាយ៉ាងនេះក្ដី ដោយសារតែមានការកើនឡើងនូវការទាយស្មាន និងព័ត៌មានមិនត្រឹមត្រូវកាន់តែច្រើន ដែលត្រូវបានចេញផ្សាយនៅក្នុងសារព័ត៌មាន និងនៅលើគេហទំព័រមួយចំនួន ទើបត្រូវបញ្ចេញនូវព័ត៌មានដូចតទៅ ដោយមិនប៉ះពាល់ទៅដល់ បញ្ហាគតិយុត្តិ ដែលត្រូវដោះស្រាយនៅក្នុងដីកា

របស់ជនរងគ្រោះនេះ នៅពេលសម្រេចអំពីភាពគ្រប់គ្រាន់ នៃភស្តុតាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយសារតែការដែលសហចៅក្រមស៊ើបអង្កេត មិនបានដាក់បង្ហាញព័ត៌មានដ៏សំខាន់ ឲ្យបានទាន់ពេលវេលានោះ ធ្វើឲ្យប៉ះពាល់ដល់លទ្ធភាព របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការធ្វើការស៊ើបអង្កេតឲ្យបានទាន់ពេលវេលា វិភាគឲ្យបានត្រឹមត្រូវទៅលើភស្តុតាងពាក់ព័ន្ធ និងផ្តល់ព័ត៌មានលម្អិតអំពីព្យសនកម្មដែលពាក់ព័ន្ធ។

56. ដីកាស្តីពីភាពអាចទទួលយកបាន បានបដិសេធពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានចំនួនបួន ទាក់ទងភាពគ្រប់គ្រាន់ ឬគុណភាពនៃព័ត៌មានដែលបានផ្តល់ឲ្យ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖(១) មិនមានការបង្ហាញថា ជនរងគ្រោះទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់" (មូលដ្ឋានទី៣) (២) អ្នកដាក់ពាក្យសុំស្ថិត ក្រៅវិសាលភាពនៃពេលវេលានៃសំណុំរឿង (មូលដ្ឋានទី៥) (៣) ពាក្យសុំតាំងខ្លួនមិនមានរយៈពេល ឬទីតាំងគ្រប់គ្រាន់ ដើម្បីអាចទទួលយកក្នុងសំណុំរឿង (មូលដ្ឋានទី៦) ឬ (៤) សក្ខីកម្មមិនស្របគ្នាជាមួយភស្តុតាង ឬមិនស៊ីសង្វាក់គ្នា (មូលដ្ឋានទី៧)។ ការសម្រេចបែបនេះគឺ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រព្រឹត្តកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ។ ជាឧទាហរណ៍ នៅក្នុងការបដិសេធដើមបណ្តឹងរដ្ឋប្បវេណីមួយ តាមមូលដ្ឋានទី៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងដោយកម្រិតទៅលើអង្គហេតុ ដោយពិចារណាតែទៅលើការសម្លាប់ណា ដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ដោយមិនបានពិចារណាអំពីភស្តុតាង នៃឧក្រិដ្ឋកម្មជាច្រើនផ្សេងៗទៀត ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង០០៤ ដែលកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ[139]។ ក្នុងករណីផ្សេងទៀត

ដំណោះស្រាយឡើយ។ [...] នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ សហព្រះរាជអាជ្ញា មិនមានគោលជំហរផ្លូវច្បាប់ណាមួយ ក្នុងការជូនដំណឹងដល់សាធារណជន អំពីទីតាំងឧក្រិដ្ឋកម្មដទៃទៀតឡើយ ដូច្នេះហើយទើបមានតែព័ត៌មាន ដែលផ្តល់ដោយសហចៅក្រមស៊ើបអង្កេត ទើបមានភាពពាក់ព័ន្ធ")។

[139] សូមមើល ជាឧទាហរណ៍ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេចលើភាពមិនអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាន់ សាន (11-VSS-00178) និងសហមេធាវី សម្រាប់ការដាក់សារណា នៅក្នុងឧបសម្ព័ន្ធ ច។ សំណុំរឿង ០០៤ ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេនី ឧបសម្ព័ន្ធ ច ៖ ទឡ្ហីករណ៍លើភាពអាចទទួលយកបាន របស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិន

តាមមូលដ្ឋានទី៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់ដោយខុសឆ្គង នូវកាលបរិច្ឆេទ និងទីតាំងគន្លឹះនានាថា "មិនជាក់លាក់" ពេលដែលកាលបរិច្ឆេទ និងទីតាំងគន្លឹះទាំងនោះ ត្រូវបានរៀបរាប់យ៉ាងលម្អិតគ្រប់គ្រាន់ពិតប្រាកដ នៅក្នុងឯកសារ ដែលរួមមាននូវពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបំពេញតាមបទដ្ឋានបង្ហាញភស្តុតាង ដែលបានតម្រូវសម្រាប់ភាពអាចទទួលយកបាន[140]។ ដូចគ្នានេះ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ត្រូវបានសម្រេចថាមិនអាចទទួលយកបានផ្នែកខ្លះ តាមមូលដ្ឋានទី៧ ដែលភាពមិនស៊ីសង្វាក់គ្នាជាក់លាក់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់នោះ គឺមិនមានភាពច្បាស់លាស់ ហើយការពិនិត្យមើលដោយត្រឹមត្រូវទៅលើភស្តុតាង បង្ហាញថាមិនមានភាពមិនស៊ីសង្វាក់គ្នា ឬភាពមិនស៊ីសង្វាក់គ្នាដែលបានអះអាងនោះ គឺតូចតាចមិនសំខាន់ ដែលមិនមែនជាកត្តាកំណត់ សម្រាប់ការសម្រេចលើភាពអាចទទួលយកបាននោះទេ[141]។

57. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការពឹងផ្អែកទៅលើមូលដ្ឋានទាំងអស់នេះ សម្រាប់ការសម្រេចបដិសេធ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណ នៅក្នុងឧបសម្ព័ន្ធ ឆ(១) និង ឆ(២) (ទន្លឹករណីនៃភាពអាចទទួលយកបាន សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែពុំមានភស្តុតាង ឬមូលដ្ឋានពាក់ព័ន្ធគ្រប់គ្រាន់)។ កំហុសឆ្គងនីមួយៗ ត្រូវបានកំណត់ភ្ជាប់ជាមួយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ នៅក្នុងឧបសម្ព័ន្ធទាំងនេះ ហើយសម្រាប់មូល

---

អាចទទួលយកបាន ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់ ឬដោយសារមូលដ្ឋានពាក់ព័ន្ធ (ដាក់ជាឯកសារភ្ជាប់ជាមួយ សារណា បណ្តឹងឧទ្ធរណ៍នេះ) [ចាប់ពីពេលនេះទៅគឺ "ឧបសម្ព័ន្ធ ច"]។

[140] សូមមើល ជាឧទាហរណ៍ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេចលើភាពមិនអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សៅ គឹមសៀង (16-VSS-00077) និងសហមេធាវី សម្រាប់សារណាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅក្នុងឧបសម្ព័ន្ធ ច។ សំណុំរឿង ០០៤ ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។ ឧបសម្ព័ន្ធ ច។

[141] សូមមើល ជាឧទាហរណ៍ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេចលើភាពមិនអាចទទួលយកបានរបស់ អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មុំ មន្នី (13-VSS-00566) ព្រំ សាន (11-VSS-00264) និង ឡុង ឈឿម (11-VSS-00308) និងសហមេធាវីសម្រាប់សារណាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅក្នុងឧបសម្ព័ន្ធ ច។ សំណុំរឿង ០០៤ ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។ ឧបសម្ព័ន្ធ ច។

ហេតុដែលបានបញ្ជាក់ជូននៅទីនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើឱ្យអង្គបុរេជំនុំជម្រះ ច្រានចោលការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពមិនអាចទទួលយកបាន ហើយផ្តល់នូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដល់ជនរងគ្រោះទាំងអស់នេះ។

## ខ. មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍៖ ការបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿង០០៤/១ ពីសំណុំរឿង០០៤/២ មិនគួរកម្រិតនៅលើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ

58. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយដោយមិនត្រឹមត្រូវ នូវដីកាបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/១ និង០០៤/២ ថាបានកម្រិតដល់លទ្ធភាពរបស់គាត់ ក្នុងការពិចារណាទៅលើឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង០០៤ ដែលធំទូលាយ មុនពេលបំបែកកិច្ចដំណើរការនីតិវិធី ដូចជាឧក្រិដ្ឋកម្មដែលប្រព្រឹត្ត នៅក្រៅភូមិភាគពាយ័ព្យ ដែលដូច្នេះហើយទើបបណ្តាលឱ្យមាន បុរេនិច្ឆ័យយ៉ាងធ្ងន់ធ្ងរ ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍។

59. នៅថ្ងៃទី១៦ ខែធ្នូឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានចេញ*ដីកាសម្រេច បំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤*ដោយបំបែក អោ អាន ចេញពីសំណុំរឿង ០០៤ និងបង្កើតសំណុំរឿង ០០៤/២[142]។ នៅក្នុងដីកាសម្រេចបំបែកសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេត បានអះអាងថាពួកគាត់ "ជឿជាក់ថា ការបំបែកសំណុំរឿងនេះ នឹងចៀសវាងមិនឱ្យមានការពន្យាពេលសំណុំរឿង អោ អាន ឱ្យយូរហួសឡើយ *ហើយក៏មិនប៉ះពាល់ដល់សិទ្ធិ របស់ភាគីណាមួយឡើយ* ខណៈដែលអង្គហេតុដែលសេសសល់ទាំងអស់ នៅក្នុងសំណុំរឿង ០០៤ នៅបន្តស៊ើបសួរ"[143]។ ប្រហែលគ្នានេះនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានចេញ *ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤* (រួមគ្នាជាមួយដីកាសម្រេចបំបែកសំណុំរឿង អោ អាន ហៅថា "ដីកាសម្រេចបំបែកសំណុំរឿង") ដោយសម្រេចថា "ដើម្បីជាប្រយោជន៍ភាគីទាំងអស់ គឺត្រូវបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤"[144]។ ដូចដែលបានបង្ហាញជាភស្តុតាង ដោយដីកាសម្រេចដែលរងការជំទាស់រួចហើយ វិសាលភាពសម្រាប់ ការ

---

[142] សំណុំរឿង ០០៤/២ ឯកសារ **D334/1** ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៦ [ចាប់ពីពេលនេះទៅហៅថា ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២]

[143] ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ កថាខណ្ឌ ៤ (ដោយគូសបញ្ជាក់បន្ថែម)។

[144] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក-កសចស ឯកសារ **D286/7** ដីកាសម្រេចបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ៥ [ចាប់ពីពេលនេះទៅហៅថា "ដីកាសម្រេចបំបែកសំណុំរឿង ០០៤/១"]

ទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ក្នុងសំណុំរឿង០០៤ បន្ទាប់ពីមានដីកាសម្រេចបំបែកសំណុំរឿង គឺកម្រិតត្រឹមតែ "អ្នកដាក់ពាក្យសុំ ដែលទទួលរងព្យសនកម្ម នៅភូមិភាគពាយ័ព្យ ពីដើមឆ្នាំ១៩៧៧ ឬពាក់កណ្តាលឆ្នាំ១៩៧៧ ដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩" គោលនយោបាយទូទាំងប្រទេស ក្នុងការលុបបំបាត់ខ្មែរក្រោម គោលនយោបាយធ្វើបាបនៅ មន្ទីរសន្តិសុខ វត្តប្រធាតុ និងទីតាំងឧក្រិដ្ឋកម្មទាំងប្រាំមួយ ដែលបានកំណត់អត្តសញ្ញាណ នៅក្នុងភូមិភាគនិរតី[145] ។ ក្នុងការសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកាត់បន្ថយយ៉ាងច្រើន នូវវិសាលភាពពេលវេលា និងវិសាលភាពភូមិសាស្ត្រ ដែលពីដំបូងគ្រប់ដណ្តប់ដោយ ឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់ ក្នុងសំណុំរឿង០០៤ ដោយបានរារាំងប្រកបដោយប្រសិទ្ធិភាព ដល់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីមុន មិនឱ្យពួកគេបន្តចូលរួម ក្នុងកិច្ចដំណើរការនីតិវិធី។

60. ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើអានុភាពនៃដីកាសម្រេចបំបែកសំណុំរឿង ទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនោះ គឺប្រឆាំងជាមួយសិទ្ធិរបស់ជនរងគ្រោះ ដែលតម្រូវថាតុលាការត្រូវ ប្រើប្រាស់ទស្សនៈទូលាយ សម្រាប់ភាពអាចទទួលស្គាល់ ជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ថា ផ្អែកលើគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក វិធានផ្ទៃក្នុងត្រូវបកស្រាយ ក្នុងន័យការពារដល់ផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ[146]។ ជាពិសេស ដោយផ្អែកទៅលើ គោលដៅរបស់ អ.វ.ត.ក ក្នុងការបង្រួបបង្រួមជាតិ អង្គជំនុំជម្រះ និងចៅក្រមរបស់ អ.វ.ត.ក "ត្រូវតែយកចិត្តទុកដាក់ជាពិសេស និងធានានូវការចូលរួមប្រកបដោយអត្ថន័យ របស់ជនរងគ្រោះ នៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត"[147]។ ដីកាសម្រេចដែលរងការជំទាស់ បានអនុវត្តផ្ទុយពីគោលដៅនេះយ៉ាងច្បាស់ក្រឡែត ដោយកម្រិតកំណត់យ៉ាង

[145] សំណុំរឿង ០០៤ ឯកសារ **D384** ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ៣៧។

[146] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[147] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបឋម *ខាងលើ*។

ខ្លាំង ទៅលើវិសាលភាពនៃភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤។

61. ជាការគួរឱ្យកត់សម្គាល់ សហចៅក្រមស៊ើបអង្កេត មិនបានបង្ហាញជាមុនឡើយថា ដីកាសម្រេចបំបែកសំណុំរឿង នឹងជះឥទ្ធិពលអាក្រក់ទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កុំថាឡើយដល់ទៅលក្ខណៈទាំងស្រុងបែបនេះ។ ជាបញ្ហាបឋម សហចៅក្រមស៊ើបអង្កេត មិនបានពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីតំណាងពួកគេ មុនពេលចេញដីកាសម្រេចបំបែកសំណុំរឿងឡើយ បើទោះបីជាវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង តម្រូវថាភាគីទទួលបានឱកាសក្នុងការដាក់សារណាលើបញ្ហា[148]។ ដីកាសម្រេចបំបែកសំណុំរឿង មិនបានរួមបញ្ចូលនូវសេចក្តីសម្រេច ដោយមានសំអាងហេតុណាមួយ របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងគោលជំហររបស់សហចៅក្រមស៊ើបអង្កេត ចំពោះវិសាលភាពនៃសំណុំរឿង ០០៤សំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២ ជាធាតុផ្សំដែលតម្រូវដោយវិធានផ្ទៃក្នុង[149]។ ជាកិច្ចការរដ្ឋបាលវិញ អង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក នៅតែបន្តចុះឈ្មោះ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ជាអ្នកដាក់ពាក្យសុំសំណុំរឿង០០៤ ដោយមិនបានញែកដាច់ពីគ្នា ទៅតាមសំណុំរឿងដែលបំបែកឡើយ។ តាមពិតទៅរហូតដល់ពេលចេញដីកាសម្រេចដែលរងការជំទាស់ អានុភាពជាក់លាក់តែមួយ នៃដីកាសម្រេចបំបែកសំណុំរឿង ចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺកាលបរិច្ឆេទដាច់ពីគ្នា សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបណ្តាលមកពីការបញ្ចប់កិច្ចស៊ើបអង្កេត តែប៉ុណ្ណោះ[150]។

[148] វិធាន ៦៦ ស្ទួន(២) នៃវិធានផ្ទៃក្នុងចែងថា ("មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត ត្រូវជូនដំណឹង អំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត។ ភាគីទាំងអស់ ត្រូវដាក់សារណាក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ")។

[149] វិធាន ៦៦ ស្ទួន(៣) នៃវិធានផ្ទៃក្នុងចែងថា ("សហចៅក្រមស៊ើបអង្កេត ត្រូវកំណត់អំពីអានុភាព នៃសេចក្តីសម្រេចដែលបានធ្វើឡើង អនុលោមតាមអនុវិធាន (១) ខាងលើ ទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ")។

[150] ដីកាសម្រេចបំបែកសំណុំរឿង បានបង្កើតនូវភាពអយុត្តិធម៌ ផ្នែកនីតិវិធីបន្ថែមទៀត សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយជម្រុញឱ្យមានកាលបរិច្ឆេទកំណត់ផ្សេងគ្នា សម្រាប់ការចូលរួមនៅក្នុង កិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤ ដែលមានបីផ្សេងពីគ្នា។ សហចៅក្រមស៊ើបអង្កេត បានបញ្ចប់កិច្ចស៊ើបសួរ និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦។ សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក-កសចស ឯកសារ **D286/7** ដីកាសម្រេចបំបែក

62. ដីកាសម្រេចដែលរងការជំទាស់ បានបដិសេធជារួម ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបើសិនមិនមានការបំបែកសំណុំរឿង ០០៤/២ និង០០៤/១ ទេ នឹងត្រូវទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៤ ហើយការណ៍នេះគឺផ្ទុយទៅនឹងការប្រកាសដោយផ្ទាល់របស់ដីកាសម្រេចបំបែកសំណុំរឿងដែលថា ការចេញដីកាសម្រេចនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ របស់ភាគីណាមួយឡើយ[151] ហើយថា ការបំបែកសំណុំរឿង គឺដើម្បីផលប្រយោជន៍របស់ភាគីទាំងអស់[152]។ ផ្ទុយទៅវិញដីកាសម្រេចបំបែកសំណុំរឿង ក្លាយជាកត្តាកំណត់នៃភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ក្រុមអ្នកដាក់ពាក្យសុំជាច្រើន រួមទាំងម្ចាស់បណ្តឹងឧទ្ធរណ៍ផងដែរ។ ជាលទ្ធផលនៃដីកាសម្រេចបំបែកសំណុំរឿង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាទៅលើការចោទប្រកាន់ទ្រង់ទ្រាយធំ នៅក្នុងសំណុំរឿង០០៤ ដើម ដូចជាទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅភូមិភាគកណ្តាល ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ហើយពិចារណាតែទៅលើការចោទប្រកាន់នានា ដែលគាត់ពិចារណាថាស្ថិតនៅក្នុង ដែនសមត្ថកិច្ចដែលបានកម្រិត ក្នុងសំណុំរឿង០០៤[153]។ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី មិនគួរត្រូវបានបដិសេធនូវ ឋានៈដែលត្រឹមត្រូវរបស់ពួកគាត់ នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០៤ ដោយផ្អែកលើមូលដ្ឋាននេះឡើយ។ ការសម្រេចផ្ទុយពីនេះ គឺអនុញ្ញាតឲ្យមានការអនុវត្តនីតិវិធីជាធម្មតា ក្នុងគោល

---

សំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ (ចាប់ពីពេលនេះទៅហៅថា "ដីកាសម្រេចបំបែកសំណុំរឿង ០០៤/១")។ កាលបរិច្ឆេទសម្រាប់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៃសំណុំរឿង០០៤/១ គឺថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦។ សូមមើលវិធាន ២៣ ស្ទួន(២) នៃវិធានផ្ទៃក្នុង (ចែងថា ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ (១៥)ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរ តាមផ្លូវតុលាការ)។ ក្នុងសំណុំរឿង អោ អាន (សំណុំរឿង ០០៤/២) សហចៅក្រមស៊ើបអង្កេតបានបំបែក កិច្ចដំណើរការនីតិវិធី ហើយបានបញ្ចប់ជាបឋម នូវកិច្ចស៊ើបសួរប្រឆាំង អោ អាន នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។ សំណុំរឿង ០០៤/២ ឯកសារ **D334/1** ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ [ចាប់ពីពេលនេះទៅហៅថា "ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ "]។ កាលបរិច្ឆេទសម្រាប់ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿង០០៤/២ គឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ផ្ទុយពីនេះ សហចៅក្រមស៊ើបអង្កេត មិនបានបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០៤ ប្រឆាំងជនត្រូវចោទដែលនៅសល់គឺ យឹម ទិត្យ រហូតដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ដែលអនុញ្ញាតឲ្យជនរងគ្រោះ អាចដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧។

[151] ដីកាសម្រេចបំបែកសំណុំរឿង ០០៤/២ កថាខណ្ឌ ៤។

[152] ដីកាសម្រេចបំបែកសំណុំរឿង ០០៤/១ កថាខណ្ឌ៥។

[153] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៧ (កម្រិតភាពអាចទទួលយកបាន ត្រឹមតែគោលនយោបាយបួន ដែលបានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យ ដែលត្រូវបានចោទប្រកាន់ថា យឹម ទិត្យ មានការទទួលខុសត្រូវ)។

បំណងពន្លឿនកិច្ចដំណើរការនីតិវិធី គឺបានដកហូតសិទ្ធិជនរងគ្រោះ ក្នុងការចូលរួមប្រកបដោយប្រសិទ្ធិភាព នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្ម និងគោលនយោបាយ ដែលត្រូវបានចោទប្រកាន់ ដែលបានធ្វើឲ្យពួកគេទទួលរង នូវព្យសនកម្មយ៉ាងធំធេង។

63. ដោយផ្អែកលើការបកស្រាយខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដល់អង្គបុរេជំនុំជម្រះសម្រេចថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើដីកាសម្រេចបំបែកសំណុំរឿង គឺបង្កព្យសនកម្មមិនអាចអនុញ្ញាតបាន ចំពោះសិទ្ធរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ហើយស្នើដល់អង្គបុរេជំនុំជម្រះបដិសេធចោល ដីកាស្តីពីភាពអាចទទួលយកបាន។ ដូចដែលបានរៀបរាប់លម្អិតនៅក្នុង ឧបសម្ព័ន្ធ ខ, គ និង ង ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលបានរៀបរាប់ឈ្មោះមួយចំនួន បានទទួលរងការខូចខាត ដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៤ មុនពេលបំបែកសំណុំរឿង។

## VI. សេចក្តីសន្និដ្ឋាន

64. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលើកឡើងថា ដីកាស្តីពីភាពអាចទទួលយកបានមានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ក។

65. ដោយផ្អែកលើការបកស្រាយខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមគោរពស្នើសុំឲ្យអង្គបុរេជំនុំជម្រះ៖

(១) សម្រេច ជាបញ្ហាបឋម ថា អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូប នៅក្នុងសំណុំរឿង០០៤ រួមទាំងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ក បន្តអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលមិនមានសេចក្តីសម្រេច ដោយមតិភាគច្រើនលើសលប់ របស់អង្គបុរេជំនុំជម្រះ ដែលសម្រេចផ្ទុយពីនេះ ឬជាជម្រើសមួយទៀត

(២) សម្រេចច្រានចោលដីកាស្តីពីភាពអាចទទួលយកបាន ដោយសារតែកំហុសអង្គហេតុ និងអង្គច្បាប់ ហើយពិចារណាឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងឧបសម្ព័ន្ធ ក ផ្អែកលើបទដ្ឋានស្តីពីភាពអាចទទួលយកបានសមស្រប រាប់បញ្ចូល

ទាំងការពិចារណាទៅលើភាពពាក់ព័ន្ធ នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅក្រៅភូមិភាគពាយ័ព្យ និងទីតាំងជាក់លាក់ទាំងប្រាំមួយ ក្នុងភូមិភាគនិរតី

(៣) ទទួលយកព័ត៌មានបន្ថែមនានា ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូន

(៤) ផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងអស់ និង

(៥) ជាជម្រើសមួយផ្សេងទៀត ទទួលស្គាល់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ ជា "ដើមបណ្តឹង/អ្នកប្តឹង"។

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | ជេត វណ្ណលី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | ហុង គឹមសួន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | ឡោ ជុនធី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | សំ សុគង់ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | ស៊ិន ស៊ុវ៉ន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | ទី ស្រ៊ីនណា | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | វ៉ែន ពៅ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | Martine JACQUIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |   |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | Daniel MCLAUGHLIN | សាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក |  |
| ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ | Nushin SARKARATI | សាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក |  |